គម្រោងកែលម្អរដ្ឋបាលមូលដ្ឋាននៅកម្ពុជា

# សៀវភៅណែនាំស្តីពីការវាយតម្លៃការបណ្តុះបណ្តាល

- ជំហានទាំងប្រាំនៃការវាយតម្លៃការបណ្តុះបណ្តាល
- ជំហាន១៖រកឱ្យឃើញនូវគោលបំណងនៃការវាយតម្លៃ
- ជំហាន២៖ ជ្រើសរើសវិធីសាស្ត្រវាយតម្លៃ
- ជំហាន៣៖ បង្កើតឧបករណ៍វាយតម្លៃ
- ជំហាន៤៖ ប្រមូលទិន្នន័យ
- ជំហាន៥៖ វិភាគ និងធ្វើរបាយការណ៍ពីលទ្ធផល

# មាតិកា

ជំហានទាំងប្រាំនៃការវាយតម្លៃ...........................................................................................៤

ជំហាន ១: រកឱ្យឃើញនូវគោលបំណងនៃការវាយតម្លៃ..............................................................៦

ជំហាន ២: ជ្រើសរើសវិធីសាស្ត្រវាយតម្លៃ..........................................................................................៩

ជំហាន ៣: បង្កើតឧបករណ៍វាយតម្លៃ...............................................................................................១៣

ជំហាន ៤: ប្រមូលទិន្នន័យ..........................................................................................................៣០

ជំហាន ៥: វិភាគ និងធ្វើរបាយការណ៍លទ្ធផល.................................................................................៣៤

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១:ទម្រង់បញ្ជីសំណួរគំរូ

ឧបសម្ព័ន្ធ ២:ទម្រង់បញ្ជីសំណួរតេស្តមុនវគ្គ/ក្រោយវគ្គ

ឧបសម្ព័ន្ធ ៣:បញ្ជីសំណួរអង្កេតលើផលប៉ះពាល់

ឧបសម្ព័ន្ធ ៤:តារាងបញ្ចូលទិន្នន័យ

ឧបសម្ព័ន្ធ ៥:បញ្ជីផ្ទៀងផ្ទាត់សម្រាប់របាយការណ៍វាយតម្លៃ

# សន្ទានុក្រម

| | |
|---|---|
| ការវាយតម្លៃ : | ការវាយតម្លៃគឺជាការកំណត់ដែលមានលក្ខណៈជាប្រព័ន្ធទៅលើគុណសម្បត្តិ តម្លៃ និងសារៈសំខាន់ទៅលើអ្វីមួយ រឺនរណាម្នាក់ដោយប្រើប្រាស់នូវល័ក្ខខ័ណ្ឌទាក់ទងនឹងបណ្តុំមាត្រដ្ឋាននានា ។ |
| វិធីសាស្ត្រវាយតម្លៃ : | វិធីសាស្ត្រវាយតម្លៃគឺជាវិធីសាស្ត្រីគោលការណ៍នានាដែលប្រើប្រាស់ទាំងវិធីសាស្ត្របែបគុណភាព និងវិធីសាស្ត្របែបបរិមាណរួមមានករណីសិក្សា ការស្រាវជ្រាវដោយធ្វើ អង្កេត ការវិភាគបែបស្ថិតិ និងគំរូដែលបង្កើតផ្សេងៗទៀត ។ |
| ឧបករណ៍វាយតម្លៃ : | ឧបករណ៍វាយតម្លៃប្រើប្រាស់ដើម្បីប្រមូលទិន្នន័យ ។ ឧបករណ៍ទាំងនោះមានច្រើនទម្រង់ ហើយយើងអាចបែងចែកវាចេញជាផ្នែកផ្សេងៗដូចជា កំរងសំណួរ ការធ្វើអង្កេត ការធ្វើតេស្ត ការធ្វើសម្ភាសន៍ ការពិភាក្សាក្រុមគោលដៅ ការសង្កេត និងកណត់ហេតុផ្សេងៗ ។ |
| ការអង្កេតពីផលប៉ះពាល់: | ការអង្កេតពីផលប៉ះពាលគឺជាឧបករណ៍វាយតម្លៃមួយដើម្បីវាស់វែងពីវិសាលភាពលើ ជំនាញ និងចំណេះដឹងដែលទទួលបានក្នុងកម្មវិធីដែលប្រែក្លាយតវិយាបទ និងលទ្ធផលចុងក្រោយឱ្យប្រសើរឡើង ដោយសារតែសិក្ខាកាមបានចូលរួមកម្មវិធីបណ្តុះបណ្តាល ។ |
| តេស្តមុនវគ្គ និងក្រោយវគ្គ : | តេស្តមុន/ក្រោយវគ្គ គឺជាទម្រង់ធម្មតានៃការវាយតម្លៃការបណ្តុះបណ្តាល ដើម្បីដឹងពីការកើនឡើងចំណេះដឹងរបស់សិក្ខាកាម ។ គេអាចប្រើតេស្តមុនវគ្គ និងតេស្តក្រោយវគ្គដើម្បីបង្ហាញពីពិន្ទុមុនវគ្គបណ្តុះបណ្តាល និងក្រោមវគ្គបណ្តុះបណ្តាល ។ |
| បញ្ជីសំណួរ | បញ្ជីសំណួរគឺជាឧបករណ៍ដ៏សាមញ្ញមួយដើម្បីវាយតម្លៃលើកម្មវិធីបណ្តុះបណ្តនានា ។ ទម្រង់សំណួរអាចត្រូវបានគេប្រើដើម្បីទទួលបានព័តិមានស្តីពីអារម្មណ៍របស់សិក្ខាកាម ។ |
| ការសម្ភាសន៍បែបពាក់កណ្តាលរចនាសម្ព័ន្ធ: | ការសម្ភាសន៍បែបពាក់កណ្តាលរចនាសម្ពន្ធ័គឺជាការសម្ភាសន៍ជាមួយបុគ្គលម្នាក់ រឺបុគ្គលនានាដោយអនុវត្តតាមបញ្ជីសំណួរដែលបានរៀបចំទុកមុន ។យើងអាចមានការផ្លាស់ប្តូរដោយលើកយកនូវសំណួរថ្មីមកសួរក្នុងពេលសម្ភាសន៍អាស្រ័យលើចម្លើយរបស់អ្នកដែលយើងធ្វើការសម្ភាសន៍ ។ |

# ១ ជំហានទាំងប្រាំនៃការវាយតម្លៃការបណ្តុះបណ្តាល

## តើអ្វីជាការវាយតម្លៃការបណ្តុះបណ្តាល ?

គេបានផ្តល់និយមន័យជាច្រើនអំពីការវាយតម្លៃ ហើយខាងក្រោមនេះគឺជានិយមន័យសាមញ្ញខ្លះៗអំពីការវាយតម្លៃ ។

ការវាយតម្លៃគឺជាការប៉ាន់ប្រមាណដែលមានលក្ខណៈជាប្រព័ន្ធ និងជាគោលដៅលើគម្រោងដែលកំពុងបន្តរឺគម្រោងដែលបានបញ្ចប់ លើកម្មវិធី រឺលើគោលនយោបាយ លើការបង្កើតគម្រោង ការអនុវត្តគម្រោង និងលទ្ធផលនានារបស់គម្រោង ។ គោលបំណងនៃការវាយតម្លៃគឺកំណត់លើភាពជាប់ទាក់ទង និងលទ្ធផលសម្រេចបានលើ គោលបំណង ការអភិវឌ្ឍ ប្រសិទ្ធភាព ផលប៉ះពាល់ និងស្ថេរភាព ។

*ប្រភព: Glossary of Key Terms in Evaluation and Results Based Management*

ការវាយតម្លៃកម្មវិធីគឺជាការប្រមូលព័ត៌មានដែលមានលក្ខណៈជាប្រព័ន្ធពីសកម្មភាព ចរិកលក្ខណៈ និងទិន្នផលរបស់កម្មវិធីដើម្បីធ្វើការកែតម្រូវកម្មវិធី បង្កើនប្រសិទ្ធភាពកម្មវិធី និង/រឺ ផ្តល់ជាព័ត៌មានសម្រាប់ធ្វើសេចក្តីសម្រេចចិត្តលើកម្មវិធីនាពេលអនាគត ។

*ប្រភព: Patton, M.Q. (1997). Utilization-focused Evaluation: The New Century Text (3rd ed.). Thousand Oaks, CA: Sage.*

## វដ្តនៃការគ្រប់គ្រងការបណ្តុះបណ្តាល

គេអាចបែងចែកវដ្តនៃការគ្រប់គ្រងការបណ្តុះបណ្តាលជាបីជំហានសំខាន់ៗ: ជំហាន១:ផែនការ ជំហាន២: ការអនុវត្ត និងជំហាន៣: ការវាយតម្លៃ ។ ការវាយតម្លៃគឺជាជំហានចុងក្រោយនៃ វដ្តនៃការគ្រប់គ្រងការបណ្តុះបណ្តាល ។ លទ្ធផលនៃការវាយតម្លៃការបណ្តុះ បណ្តាលឆ្លុះបញ្ចាំងពីជំហានបន្ទាប់នៃការធ្វើផែនការបណ្តុះបណ្តាលដើម្បីកែលម្អកម្មវិធីបណ្តុះបណ្តាល នាពេលអនាគតដូចគំនូសព្រួញដែលបង្ហាញក្នុងគំនូសតាង ។



## ជំហានទាំងប្រាំនៃការវាយតម្លៃការបណ្តុះបណ្តាល

គេអាចបែងចែកដំណើរការនៃការវាយតម្លៃការបណ្តុះបណ្តាលជាប្រាំជំហាន ដូចខាងក្រោម : រកឱ្យឃើញនូវគោលបំណងនៃការវាយតម្លៃ ជ្រើសរើសវិធីសាស្ត្រនៃការវាយតម្លៃ បង្កើតឧបករណ៍សម្រាប់វាយតម្លៃ ប្រមូលទិន្នន័យ និងវិភាគ និងធ្វើរបាយការណ៍លទ្ធផល ។




***ជំហាន១: រកឱ្យឃើញនូវគោលបំណងនៃការវាយតម្លៃ***

- មុននឹងបង្កើតប្រពន្ធ័វាយតម្លៃ គេត្រូវកំណត់គោលបំណងនៃការវាយតម្លៃ
- ហេតុអ្វីបានជាយើងត្រូវធ្វើការវាយតម្លៃកម្មវិធី ?

***ជំហាន ២:ជ្រើសរើសវិធីសាស្ត្រវាយតម្លៃ***

- ការវាយតម្លៃកម្មវិធីបណ្តុះបណ្តាលទាំងបួនកម្រិតរបស់ Kirkpatrick
- ការឆ្លើយតប ការសិក្សា ឥរិយាបទ និងលទ្ធផល

***ជំហាន ៣:បង្កើតឧបករណ៍វាយតម្លៃ***

- បញ្ជីសំណួរ
- តេសមុន/ក្រោយវគ្គ
- ការអង្កេតលើផលប៉ះពាល់

***ជំហាន ៤:ការប្រមូលទិន្នន័យ***

- តើប្រមូលទិន្នន័យដោយរបៀបណា នៅពេលណា ដោយនរណា?

***ជំហាន ៥:វិភាគ និងធ្វើរបាយការណ៍លទ្ធផល***

- ការវិភាគទិន្នន័យវាយតម្លៃ
- ការធ្វើរបាយការណ៍

# ២ ជំហាន១: រកឱ្យឃើញនូវគោលបំណងនៃការវាយតម្លៃ

**ជំហាន ១:** រកឱ្យឃើញនូវគោលបំណងនៃការវាយតម្លៃ → **ជំហាន ២:** ជ្រើសរើសវិធីសាស្ត្រនៃការវាយតម្លៃ → **ជំហាន ៣:** បង្កើតឧបករណ៍នានាសម្រាប់វាយតម្លៃ → **ជំហាន ៤:** ប្រមូលទិន្នន័យ → **ជំហាន ៥:** វិភាគ និងធ្វើរបាយការណ៍លទ្ធផល

## ហេតុអ្វីបានជាយើងចង់ធ្វើការវាយតម្លៃកម្មវិធីបណ្តុះបណ្តាល ?

មុននឹងបង្កើតប្រព័ន្ធវាយតម្លៃ យើងត្រូវកំណត់ពីគោលបំណងនៃការវាយតម្លៃសិន ។ គោលបំណងនៃការវាយតម្លៃនឹងមានផលប៉ះពាល់លើប្រភេទទិន្នន័យ និងវិធីសាស្ត្រប្រមូលទិន្នន័យ ។

### *រៀនសូត្រពីបទពិសោធដើម្បីកែលម្អអនាគត*

មូលហេតុដែលសាមញ្ញបំផុតក្នុងការវាយតម្លៃកម្មវិធីបណ្តុះបណ្តាលអាចកំណត់ពីប្រសិទ្ធភាពនៃកម្មវិធីបណ្តុះបណ្តាលដើម្បីកែលម្អកម្មវិធីនាពេលអនាគត ។ ការវាយតម្លៃអាចជួយយើងឱ្យសិក្សាពីបទពិសោធនក្នុងកម្មវិធីបណ្តុះបណ្តាលកន្លងមក ។ឧទាហរណ៍ : យើងប្រហែលជាចង់ដឹងថាផ្នែកណាមួយនៃកម្មវិធីបណ្តុះបណ្តាលទទួលបានជោគជ័យ ហើយផ្នែកណាមួយដែលមិនទទួលបានជោគជ័យ រឺថាតើយើងចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរនូវវិធីបណ្តុះបណ្តាលរឺទេ ។ យើងអាច ប្រើប្រាស់នូវបទពិសោធទាំងនេះដើម្បីធ្វើផែនការកម្មវិធីបណ្តុះ បណ្តាលឱ្យប្រសើរ ។



### *គោលបំណងត្រូវបានរកឃើញដោយក្រុមការងារ អ.រ.ម*

ក្រុមការងារ អ.រ.ម បានរកឃើញនូវគោលបំណងខាងក្រោមស្តីពីការវាយតម្លៃកម្មវិធីបណ្តុះបណ្តាលដែលក្រុមការងារធ្វើផែនការ និងអនុវត្តសម្រាប់មន្ត្រីរាជការសាធារណៈដែលទទួលខុសត្រូវលើផ្នែករដ្ឋបាលមូលដ្ឋាន ។

- កំណត់ថាតើគោលបំណងនៃការបណ្តុះបណ្តាលសម្រេចបានរឺទេ ។

- ពិនិត្យមើលថាតើជំនាញ និងចំណេះដឹងដែលទទួលបានក្នុងការបណ្តុះបណ្តាលត្រូវបានគេអនុវត្តដោយរបៀបណា ។
- ធ្វើការប៉ាន់ប្រមាណលើលទ្ធផល និងផលប៉ះពាល់នានាលើកម្មវិធីបណ្តុះបណ្តាល
- ធ្វើការប៉ាន់ប្រមាណពីប្រសិទ្ធិភាពនៃកម្មវិធីបណ្តុះបណ្តាល
- ធ្វើការប៉ាន់ប្រមាណថាតើកម្មវិធីបណ្តុះបណ្តាលត្រូវបានគេអនុវត្តបានត្រឹមត្រូវដែររឺទេ ។



*បញ្ហាគណនេយ្យភាព*

គណនេយ្យភាពអាចជាមូលហេតុមួយក្នុងការវាយតម្លៃកម្មវិធីបណ្តុះបណ្តាល ។ការវាយតម្លៃអាចបង្កើន នូវគណនេយ្យភាពរបស់ភ្នាក់ងារអនុវត្តនានាចំពោះអ្នកពាក់ពន្ធ័នានា ។ ករណីក្រុមការងារ អ.វ.ម គេអាចពង្រឹងគណនេយ្យភាពបានក្នុងនាមជា ភ្នាក់ងារបណ្តុះបណ្តាលមួយ ដោយរាយការណ៍ពីលទ្ធផលនៃការវាយតម្លៃ កម្មវិធីបណ្តុះបណ្តាលនានាដល់ក្រសួងមហាផ្ទៃ និង JICA ។

*មូលហេតុផ្សេងៗនៃការវាយតម្លៃ*

កម្មវិធីបណ្តុះបណ្តាលនិមួយៗអាចមានគោលបំណងនៃការវាយតម្លៃ
ផ្សេងៗពីគ្នាអាស្រ័យលើគោលបំណង មាតិកា សិក្ខាកាម និងកត្តាផ្សេងៗនានា ។ដូចនេះអ្នកបង្កើតការការវាយតម្លៃអាចធ្វើការកែតម្រូវកម្មវិធីបណ្តុះបណ្តាលនិមួយៗដើម្បីឱ្យត្រូវនឹងគោលបំណងនៃការវាយតម្លៃជាក់លាក់ ។ ឧទាហរណ៍ខ្លះៗដែលទាក់ទងនឹងការវាយតម្លៃកម្មវិធីបណ្តុះបណ្តាលមានបង្ហាញជូនដូចខាងក្រោម :

- កំណត់ជោគជ័យក្នុងការសម្រេចបានគោលបំណងនៃកម្មវិធី
- រកឱ្យឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយក្នុងដំណើរការអភិវឌ្ឍធនធានមនុស្ស
- ប្រៀបធៀបការចំណាយនានា និងអត្ថប្រយោជន៍នៃកម្មវិធីអភិវឌ្ឍធនធានមនុស្ស
- សម្រេចថានរណាគួរចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលនាពេលអនាគត
- សាកល្បងពីភាពច្បាស់លាស់ និងត្រឹមត្រូវនៃតេស្ត ករណីសិក្សា និងលំហាត់នានា
- រកឱ្យឃើញថាតើសិក្ខាកាមណាដែលជោគជ័យបំផុតក្នុងកម្មវិធីបណ្តុះបណ្តាល
- កំណត់ថាតើកម្មវិធីនេះជាដំណោះស្រាយសមស្របចំពោះតម្រូវការជាក់ស្តែងរឺទេ ។
- បង្កើតប្រពន្ធ័ Database ដែលអាចជួយគ្រប់គ្រងក្នុងការធ្វើសេចក្តីសម្រេចចិត្ត ។

*ប្រភព: Handbook of Training Evaluation and Measurement Methods*

**ឯកសារយោង:**

- “Chapter 2 Reasons for Evaluating” (p.16-p.20) *Evaluating Training Programs: The Four Levels.*
- “Developing a Results-Based Approach” (p.36-p.38) *Handbook of Training Evaluation and Measurement Methods.*
- “1. Overview of Evaluation” (p.1-p.p.11) *Building Evaluation*

# ៣ ជំហាន២: ជ្រើសរើសវិធីសាស្រ្តវាយតម្លៃ

**ជំហាន ១:** រកឱ្យឃើញនូវគោលបំណងនៃការវាយតម្លៃ

**ជំហាន ២:** ជ្រើសរើសវិធីសាស្រ្តនៃការវាយតម្លៃ

**ជំហាន ៣:** បង្កើតឧបករណ៍នានាសម្រាប់វាយតម្លៃ

**ជំហាន ៤:** ប្រមូលទិន្នន័យ

**ជំហាន ៥:** វិភាគ និងធ្វើរបាយការណ៍លទ្ធផល

## ការវាយតម្លៃទាំងបួនកម្រិត

ការវាយតម្លៃទាំងបួនកម្រិតគឺជាវិធីសាស្រ្តដ៏សាមញ្ញបំផុតដែលគេប្រើប្រាស់ដើម្បីវាយតម្លៃកម្មវិធីបណ្តុះបណ្តាល ។កម្រិតទាំងបួនលំដាប់នៃការវាយតម្លៃគឺជាឯកសារដើមរបស់លោក Donald L.Kirkpatrick ជាសាស្រ្តចារ្យកិត្តិយសនៃសាកលវិទ្យាល័យក Wisconsin ។ ទស្សនាទាននេះត្រូវបានគេយកទៅប្រើប្រាស់ក្នុងក្រុមហ៊ុនឯកជនដើម្បីវាយតម្លៃពីកម្មវិធីបណ្តុះបណ្តាលរបស់ខ្លួន បន្ទាប់មកត្រូវបានគេយកមកអនុវត្តក្នុងកម្មវិធីបណ្តុះបណ្តាលក្រោមគម្រោងជំនួយបច្ចេកទេសរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ។ តាមគោលគំនិតរបស់គាត់ ការកសាងសមត្ថភាពមានជំហាន: (១)ការឆ្លើយតប, (២)ការរៀន (៣) ឥរិយាបថ និង(៤)លទ្ធផល ។

**កម្រិត 4 : លទ្ធផល** — តើមានអ្វីកើតឡើងដែលជាលទ្ធផលក្រោយបញ្ចប់វគ្គ?

**កម្រិត 3 : ឥរិយាបថ** — តើសិក្ខាកាមមានការកែប្រែឥរិយាបថដូចម្តេចខ្លះ បន្ទាប់ពីបានចូលរួមវគ្គបណ្តុះបណ្តាលនេះ ?

**កម្រិត 2 : ការរៀន** — តើសិក្ខាកាមបានរៀនពីអ្វីខ្លះ ?

**កម្រិត 1 : ការឆ្លើយតប** — តើសិក្ខាកាមមានការឆ្លើយតបយ៉ាងដូចម្តេចទៅនឹងកម្មវិធីបណ្តុះបណ្តាល ?

## កម្រិត១: ការឆ្លើយតប

ការវាយតម្លៃនៅក្នុងកម្រិតនេះគឺវាស់វែងពីរបៀបដែលសិក្ខាកាមឆ្លើយតបចំពោះកម្មវិធីបណ្តុះបណ្តា។ ជាការប្រសើរណាស់ ក្នុងការទទួលបានការឆ្លើយវិជ្ជមាន ។ទោះបីជាការឆ្លើយតបវិជ្ជមានអាចមិនប្រាកដថាទទួលបានចំណេះដឹងនោះទេ ។ប្រសិនបើសិក្ខាកាមមិនបានឆ្លើយតបល្អទេនោះ ពួកគេនឹងមិនត្រូវបានគេលើកទឹកចិត្តក្នុងការរៀន ។

“ការឆ្លើយតបការវាយតម្លៃគឺដូចគ្នាដែរគឺវាយតម្លៃពីការវាយតម្លៃពីការពេញចិត្តរបស់អតិថិជន ។ ការបណ្តុះបណ្តាលដែលមានប្រសិទ្ធភាព សំខាន់គឺសិក្ខាកាមឆ្លើយតបបានល្អចំពោះការបណ្តុះបណ្តាលនោះ ។ បើមិនដូច្នោះទេគឺពួកគេមិនត្រូវបានគេលើកទឹកចិត្តក្នុងការសិក្សា ។”

*Kirkpatrick (2006) Evaluating Training Programs*

## កម្រិត២: ការរៀន

ការវាយតម្លៃក្នុងកម្រិតនេះគឺវាស់វែងពីវិសាលភាពដែលសិក្ខាកាមផ្លាស់ប្តូរឥរិយាបទ កើនឡើងចំណេះដឹង និង/រឺ កើនឡើងនូវជំនាញដោយសារតែចូលរួមកម្មវិធីបណ្តុះបណ្តាល ។ ប្រសិនបើការផ្លាស់ប្តូរជាការផ្លាស់ប្តូរឥរិយាបទនោះ វាត្រូវមានការផ្លាស់ប្តូរចំនួនមួយរឺផ្សេងទៀតកើតឡើង ។

## កម្រិត៣: ឥរិយាបទ

ការវាយតម្លៃក្នុងកម្រិតនេះវាស់វែងពីវិសាលភាពដែលសិក្ខាកាមបានផ្លាស់ប្តូរឥរិយាបទរបស់ខ្លួនដោយសារតែបានចូលរួមកម្មវិធីបណ្តុះបណ្តាល ។ មានល័ក្ខខ័ណ្ឌចំនួនបួនកើតឡើង ដើម្បីឱ្យមានការផ្លាស់ប្តូរនោះគឺ :

- សិក្ខាកាមត្រូវមានចិត្តចង់ផ្លាស់ប្តូរ
- សិក្ខាកាមត្រូវដឹងថាត្រូវធ្វើអ្វី ហើយធ្វើដោយរបៀបណា
- សិក្ខាកាមត្រូវធ្វើការក្នុងបរិយាកាសសមស្រប
- សិក្ខាកាមត្រូវបានគេផ្តល់ការសរសើរចំពោះការផ្លាស់ប្តូរ

## កម្រិត៤: លទ្ធផល

ការវាយតម្លៃក្នុងកម្រិតនេះគឺដើម្បីវាស់វែងពីលទ្ធផលចុងក្រោយដែលកើតឡើងដោយសារតែសិក្ខាកាមបានចូលរួមកម្មវិធីបណ្តុះបណ្តាល ។ ឧទាហរណ៍នានានៃលទ្ធផលចុងក្រោយរួមមាន ការកើនឡើងនូវផលិតកម្ម ការកើនឡើងនូវគុណភាព ការកើនឡើងនូវតម្លៃ ។ សូមកត់សម្គាល់ថាលទ្ធផលទាំងនេះគឺជាមូលហេតុខ្លះនៃការបង្កើតកម្មវិធីបណ្តុះបណ្តាល ។

## ការវាយតម្លៃគំរូផ្សេងៗ

ខាងក្រោមនេះគឺជាគំរូនៃការវាយតម្លៃ និងវិធីសាស្រ្តនានាខ្លះដែលរៀបរាប់ពីការវាយតម្លៃ (“5. Evaluation Models, Approaches, and Designs” *Building Evaluation Capacity*)

***វិធីសាស្ត្រទាក់ទងនឹងគោលបំណងឥរិយាបទ*** (Behavioral Objectives Approach)

- ផ្តោតលើកម្រិតដែលគោលដៅនានារបស់កម្មវិធីត្រូវសម្រេចបាន
- សំណួរគន្លឹះគឺ “តើកម្មវិធីបណ្តុះបណ្តាលមានលក្ខណៈបែបណាចំពោះអ្នកដ៏ទៃផ្សេងទៀត”

***ការឆ្លើយតបការវាយតម្លៃ***(Responsive Evaluation)

- អ្នកធ្វើការវាយតម្លៃទទួលខុសត្រូវលើតម្រូវការព័ត៌មាននានារបស់អ្នកចូលស្តាប់ និងអ្នកពាក់ពន្ធ័នានា
- សំណួរគន្លឹះគឺ “តើកម្មវិធីបណ្តុះបណ្តាលមានលក្ខណៈបែបណាចំពោះអ្នកដ៏ទៃផ្សេងទៀត”

***ការវាយតម្លៃលើគោលបំណង***(Goal-Free Evaluation)

- ផ្តោតលើលទ្ធផលជាក់ស្តែងច្រើនជាងលទ្ធផលរំពឹងទុក
- សំណួរគន្លឹះគឺ “តើមានផលប៉ះពាល់អ្វីខ្លះលើកម្មវិធី”

***Expertise/Accreditation Approaches***

- គោលបំណងគឺដើម្បីផ្តល់នូវជំនាញវិនិច្ឆ័យលើគុណភាពរបស់កម្មវិធីនានាដោយយោងលើទស្សនៈឯកទេសនានា ។
- សំណួរគន្លឹះគឺ “តើអ្នកជំនាញការណ៍ចាត់ថ្នាក់កម្មវិធីនេះយ៉ាងដូចម្តេច?”

***ការវាយតម្លៃដោយមានការចូលរួម/ការសហការណ៍ (Participatory/Collaborative Evaluation)***



- ផ្តោតទៅលើការចូលរួមរបស់អ្នកពាក់ពន្ធ័ក្នុងដំណើរការវាយតម្លៃដូចនេះគេអាចយល់ការវាយ តម្លៃកាន់តែច្បាស់ ហើយកម្មវិធីត្រូវបានគេចាប់ផ្តើមធ្វើការវាយតម្លៃ ហើយចុងក្រោយគេប្រើ ប្រាស់លទ្ធផលក្នុងការវាយតម្លៃ ដើម្បីស្នើធ្វើសេចក្តីសម្រេចចិត្ត ។
- សំណួរចម្បងគឺ “តើតម្រូវការព័តិមានអ្វីខ្លះដែលទាក់ទង នឹងកម្មវិធី ?”

***ការសិក្សាពីអង្គភាព (Organizational Learning)***

- សូមគិតថាការវាយតម្លៃគឺជាសកម្មភាពសង្គមមួយដែលការវាយតម្លៃត្រូវបានគេបង្កើតឡើងដោយមានការយល់ព្រមពីសមាជិកអង្គភាព ។
- សំណួរគន្លឹះគឺ “តើបុគ្គល ក្រុម និងអង្គភាពទូទៅនានាមានតម្រូវការលើព័ត៌មាន និងការសិក្សាអ្វីខ្លះ ?”

**ឯកសារយោង:**

- “Chapter 3 The Four Levels: An Overview” (p.21-p.26) *Evaluating Training Programs: The Four Levels.*
- “Chapter 4 A Result-Based HRD Model” (p.51-p.65) *Handbook of Training Evaluation and Measurement Methods.*
- “5. Evaluation Models, Approaches, and Designs” (p.101-p.180) *Building Evaluation Capacity.*

=

# ៤ ជំហាន៣: ការបង្កើតឧបករណ៍វាយតម្លៃ

| ជំហាន ១: រកឱ្យឃើញនូវគោលបំណងនៃការវាយតម្លៃ | ជំហាន ២: ជ្រើសរើសវិធីសាស្ត្រនៃការវាយតម្លៃ | ជំហាន ៣: បង្កើតឧបករណ៍នានាសម្រាប់វាយតម្លៃ | ជំហាន ៤: ប្រមូលទិន្នន័យ | ជំហាន ៥: វិភាគ និងធ្វើរបាយការណ៍លទ្ធផល |
|---|---|---|---|---|

## ឧបករណ៍វាយតម្លៃនានា

មានឧបករណ៍វាយតម្លៃនានាដែលអាចជ្រើសរើសបានអាស្រ័យលើគោលបំណង និងវិធីសាស្ត្រនៃការវាយតម្លៃ ។

- ទម្រង់បញ្ជីសំណួរ
- ការអង្កេត
- តេស្ត
- ការសម្ភាសន៍
- ការពិភាក្សាក្រុមគោលដៅ
- ការសង្កេត
- កំណត់ហេតុផ្សេងៗ

ចំពោះកម្មវិធីបណ្តុះបណ្តាលដែលមានគោលដៅសម្រាប់មន្ត្រីរដ្ឋបាលមូលដ្ឋាន ។ បញ្ជីសំណួរអាចត្រូវបានគេប្រើក្នុង “កម្រិត១: ការឆ្លើយតប” តេស្តមុនវគ្គ/ក្រោយវគ្គអាចត្រូវបានគេប្រើក្នុង “កម្រិត ២: ការរៀន” និងការអង្កេតផលប៉ះពាល់អាចត្រូវបានគេប្រើក្នុង “កម្រិត៣:ឥរិយាបទ” និង “កម្រិត ៤: លទ្ធផល” ។

| កម្រិត១:ការឆ្លើយតប | កម្រិត២:ការសិក្សា | កម្រិត៣:ឥរិយាបទ និង កម្រិត៤:លទ្ធផល |
|---|---|---|
| បញ្ជីសំណួរ | តេស្តមុន/ក្រោយវគ្គ | ការអង្កេតផលប៉ះពាល់ |

ជំហានទាំង៥ នៃការបង្កើតបញ្ជីសំណួរ




បញ្ជីសំណួរប្រហែលជាទម្រង់ដ៏សាមញ្ញបំផុតនៃការវាយតម្លៃកម្មវិធីនានា ។ គេអាចបង្កើតបញ្ជីសំណួរសម្រាប់ការវាយតម្លៃពីការឆ្លើយតបរបស់សិក្ខាកាមតាមជំហានទាំង៥ខាងក្រោម :

### *ជំហាន១: កំណត់អ្វីដែលយើងចង់រក*




ជំហានដំបូងនៃការបង្កើតបញ្ជីសំណួរគឺកំណត់នូវព័ត៌មាននានាដែលយើងចង់សិក្សា ។ ព័តមានចាំបាច់អាស្រ័យលើ

- ខ្លឹមសារៈ តើខ្លឹមសារសមស្របដែរឬទេ?
- សម្ភារៈ តើសម្ភារៈនានាសំខាន់ដែរឬទេ?
- វិធីសាស្ត្របង្រៀនៈ តើវិធីសាស្ត្របង្រៀនសមស្របដែរឬទេ?
- គ្រូឧទ្ទេស/អ្នកសម្របសម្រួលៈ តើគ្រូឧទ្ទេស/អ្នកសម្របសម្រួលមានប្រសិទ្ធភាពដែរឬទេ?
- លើកទឹកចិត្តក្នុងការសិក្សាៈ តើអ្នកត្រូវបានគេលើកទឹកចិត្តក្នុងការសិក្សានូវខ្លឹមសារនានាដែរឬទេ?
- ភាពជាប់ទាក់ទងនឹងកម្មវិធីៈ តើកម្មវិធីមានភាពជាប់ទាក់ទងនឹងតម្រូវការដែរឬទេ?
- កម្រិតយល់ដឹងៈ តើអ្នកយល់ពីខ្លឹមសារដែរឬទេ?
- ពេលវេលាៈ តើរយៈពេលកម្មវិធីសមស្របដែរឬទេ?
- សេវាឬឧបករណ៍នានាៈ តើសេវា និងឧបករណ៍នានាក្នុងការបណ្តុះបណ្តាលសមស្របដែរឬទេ?
- ការវាយតម្លៃជារួមៈ តើអ្នកវាយតម្លៃជារួមលើកម្មវិធីយ៉ាងដូចម្តេច?
- ការកែលម្អផែនការៈ តើអ្នកនឹងប្រើប្រាស់នូវអ្វីដែលអ្នកបានសិក្សាយ៉ាងដូចម្តេច?

សំណួរត្រូវបានគេបង្កើតនៅពេលក្រោយ ប៉ុន្តែវាមានសារសំខាន់ក្នុងការបង្កើតសំណួរទាំងនោះក្នុងទម្រង់សង្ខេប ដើម្បីឱ្យគេអាចចាត់ជាក្រុមនូវសំណួរដែលទាក់ទងគ្នា ។

### *ជំហាន២: ជ្រើសរើសប្រភេទសំណួរនានា*




ជំហានទី២ក្នុងការបង្កើតសំណួរគឺជ្រើសរើសប្រភេទសំណួរនានា ។ សំណួរដែលត្រូវសួរអាចបែងចែកជាពីផ្នែកធំៗ: សំណួរបើក និងសំណួរបិទ ។

សំណួរបើក :សំណួរបើកមានចម្លើយមិនកំណត់ ។ សំណួរសួរដោយមាន ទុកចន្លោះសម្រាប់ឆ្លើយ ។ សំណួរបើក ផ្តល់ឱកាសឱ្យសិក្ខាកាមបញ្ចេញនូវទស្សនៈរបស់ខ្លួន ។ សិក្ខាកាមបញ្ចេញនូវទស្សនៈផ្សេងៗគ្នាដែលពិបាកក្នុងការវិភាគ ។ ខាងក្រោមនេះគឺជាឧទាហរណ៍ខ្លះៗ ដែលទាក់ទងនឹងសំណួរបើក :

- តើខ្លឹមសារផ្នែកណាមួយនៃកម្មវិធីបណ្តុះបណ្តាលដែលអ្នកចាប់អារម្មណ៍ជាងគេ ?
- តើអ្នកគិតថាយើងអាចកែលម្អខ្លឹមសារកម្មវិធីបណ្តុះបណ្តាលដោយរបៀបណា?

ម្យ៉ាងវិញទៀត សំណួរបើកក៏អាចសួរឱ្យឆ្លើយនូវចម្លើយបី រឺបួនពីក្នុងតារាងផងដែរ ។ មានប្រភេទសំណួរបើកច្រើនដូចខាងក្រោម :

- ***ចម្លើយដែលមានជម្រើសពីរ:*** អ្នកឆ្លើយអាចរើសនូវចម្លើយមួយក្នុងជម្រើសចំនួនពីរ ។ ដូចជា

  បាទ-ទេ ពិត- មិនពិត និងយល់ស្រប- មិនយល់ស្រប ។ ខាងក្រោមនេះគឺជាឧទាហរណ៍ :

តើអ្នកចូលចិត្តកម្មវិធីបណ្តុះបណ្តាលដែររឺទេ?

| | | | |
|---|---|---|---|
| បាទ/ចាំ | ✓ | ទេ | |

- កំណត់ជាអត្រាកម្រិត៖ គេសួរឱ្យជ្រើសរើសនូវចម្លើយដែលសមស្របបំផុតដែលឆ្លុះបញ្ចាំងពីទស្សនៈ របស់ពួកគេដោយរើសនូវកម្រិតនានា ។ កម្រិតនានានោះអាចជាចំនួន (ឧ. លេខ ១ដល់ ១០) រឺជាពាក្យ (ឧ. យល់ស្របទាំងស្រុង រហូតដល់ មិនយល់ស្របទាំងស្រុង) ។ ខាងក្រោមនេះគឺជា ឧទាហរណ៍៖

តើអ្នកវាយតម្លៃនូវខ្លឹមសារនៃការបណ្តុះបណ្តាលយ៉ាងដូចម្តេច?

| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | ✓ | | |

- ការវាយតម្លៃដោយ Checklist៖ មានតារាងនានា ដែលគេសួរឱ្យគូសនូវចម្លើយដែលត្រូវនឹងស្ថានភាព ។ ខាងក្រោមនេះគឺជាឧទាហរណ៍៖

សូមជ្រើសរើសនូវចម្លើយមួយពីតារាងខាងក្រោមនេះដែលអ្នកចូលចិត្តបំផុតក្នុងកម្មវិធីបណ្តុះបណ្តាល ?

| | |
|---|---|
| ១.ប្រពន្ធ័រដ្ឋបាលមូលដ្ឋាន | ✓ |
| ២. គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ | |
| ៣. ច្បាប់រៀបចំអង្គការ | |

- ការវាយតម្លៃដោយកម្រិតថ្នាក់នានា៖ តម្រូវឱ្យសិក្ខាកាមកម្រិតថ្នាក់នៅក្នុងតារាងដែលមានបញ្ជីនានា ។ ខាងក្រោមនេះគឺជាឧទាហរណ៍ :

សូមដាក់ពិន្ទុលើផ្នែកនានាតាមលំដាប់នៃការពេញចិត្តរបស់អ្នក ?

| | |
|---|---|
| ១.ប្រពន្ធ័រដ្ឋបាលមូលដ្ឋាន | 2 |
| ២. គោលនយោបាយវិមជ្ឍការ និងវិសហមជ្ឈការ | 1 |
| ៣. ច្បាប់រៀបចំអង្គការ | 3 |

## *ជំហាន៣: បង្កើតបញ្ជីសំណួរ*




ជំហានទីបីក្នុងការបង្កើតបញ្ជីសំណួរគឺបង្កើតនូវសំណួរដោយយោងលើប្រភេទសំណួរដែលបានគ្រោងទុក និងប្រភេទសំណួរដែលត្រូវការនានា ។




### *សំណួរដែលល្អ*

សំណួរដែលល្អគឺសាមញ្ញ ខ្លី ច្បាស់លាស់ ហើយត្រូវចំណុចដែលចង់បានដើម្បីជៀសវាងការឆ្លើយភាន់ច្រលំ រឺដែលនាំឱ្យ អ្នកឆ្លើយឆ្លើយនូវចម្លើយដែលយើងចង់បានមួយ ។

### *ការបង្កើតបញ្ជីសំណួរដែលល្អ*

បញ្ជីសំណួរដែលបង្កើតបានល្អគឺងាយស្រួលក្នុងការយល់ និងងាយស្រួលក្នុងការឆ្លើយដែលធ្វើឱ្យអ្នកឆ្លើយ ចង់បំពេញបញ្ជីសំណួរនោះ ដោយមានការបំពេញខុសឆ្គងតែបន្តិចបន្តួចប៉ុណ្ណោះ ។

### *បញ្ជីសំណួរគំរូ*

យើងមានភ្ជាប់នូវទម្រង់បញ្ជីសំណួរនានាក្នុងសិក្ខាសាលាមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងសិក្ខាសាលាសម្រាប់មន្ត្រី អ.រ.ម ជាឯកសារយោង។ បញ្ជីសំណួរគំរូផ្សេងៗទៀតមាននៅក្នុងសៀវភៅឯកសារយោង ។

***ជំហាន៤: ការសាកល្បង***




ជំហានទីបួនក្នុងការបង្កើតបញ្ជីសំណួរគឺធ្វើតេស្តបញ្ជីសំណួរទាំងនោះ ។ វាជាការប្រសើរណាស់ប្រសិនបើបញ្ជីសំណួរដែលបានរៀបចំនោះ ត្រូវបានគេយកទៅសាកល្បងប្រើជាមួយក្រុមសិក្ខាកាមគំរូនានា ។ ប្រសិនបើមិនអាចទេ សំណួរទាំងនោះអាចយកទៅសាកល្បងជាមួយនឹង ក្រុមមនុស្សដែលមានកម្រិតការងារនោះប្រហាក់ប្រហែលនឹង សិក្ខាកាម ។



ខាងក្រោមនេះគឺជា ចំណុចខ្លះៗដែលត្រូវពិនិត្យពេលសាកល្បងបញ្ជីសំណួរទាំងនោះ

- តើគាត់យល់សំណួរនោះទាំងអស់ទេ?
- តើគាត់មានការលំបាកអ្វីខ្លះក្នុងការឆ្លើយនូវសំណួរទាំងនោះ ?
- តើគ្រប់សំណួរបើកទាំងអស់មានចម្លើយដែរឺទេ?
- តើការរំលងសំណួរមួយទៅសំណួរផ្សេងទៀតត្រូវបានគេធ្វើឡើងត្រឹមត្រូវដែរឺទេ?
- តើមានផ្នែកណាមួយដែលលើកឡើងនោះមានភាពផ្ទុយគ្នាដែរឺទេ?
- តើសំណួរដែលបានបង្កើតឡើងនោះផ្តល់នូវចំណាប់អារម្មណ៍ជាវិជ្ជមានសម្រាប់អ្នកឆ្លើយដែរឺទេ?

***ជំហាន៥: ការពិនិត្យសម្រេចលើបញ្ជីសំណួរ***




យោងតាមលទ្ធផលនៃការសាកល្បងបញ្ជីសំណួរក្នុងជំហាន៤ បញ្ជីសំណួរ/សំណួរនឹងត្រូវពិនិត្យសម្រេច។

ចំពោះទម្រង់បញ្ជីសំណួរគំរូ សូមពិនិត្យមើលឧបសម្ព័ន្ធ ១

## ជំហានទាំងប្រាំនៃការបង្កើតតេស្តមុន/ក្រោយវគ្គ




តេស្តមុនវគ្គ/ក្រោយវគ្គគឺជាទម្រង់សាមញ្ញមួយនៃការវាយតម្លៃកម្មវិធីបណ្តុះបណ្តាលនានាដើម្បីដឹងពីការកើនឡើងនូវចំណេះដឹងរបស់សិក្ខាកាម ។

### *ជំហាន១: កំណត់ពីថាតើចំណេះដឹង និងការយល់ដឹងអ្វីខ្លះដែលយើងចង់វាស់វែង?*




ជំហានដំបូងនៃការបង្កើតតេស្តមុនវគ្គ/ក្រោយវគ្គគឺកំណត់ថាតើចំណេះដឹង និងការយល់អ្វីខ្លះដែលយើងចង់វាស់វែង ។ ជាទូទៅអ្វីដែលយើងចង់វាស់គឺជាគោលគំនិតគន្លឹះ និងទស្សនៈនានាដែលបានបង្រៀនក្នុងវគ្គបណ្តុះបណ្តាល ។ឧទាហរណ៍ ក្នុងករណីការបណ្តុះបណ្តាលមន្ត្រី អ.វ.ម ដែលធ្វើឡើងក្នុងខែកក្កដា ឆ្នាំ ២០០៧ ។ ខាងក្រោមនេះគឺជាបញ្ហានានាដែលគេប្រើដើម្បីធ្វើតេស្តមុនវគ្គ/ក្រោយវគ្គ

- ប្រពន្ធ័រដ្ឋបាលមូលដ្ឋាន
  - រច្នាសម្ពន្ធ័ប្រពន្ធ័រដ្ឋបាលមូលដ្ឋាន
  - តួនាទីរដ្ឋបាលថ្នាក់ខេត្ត និងថ្នាក់ស្រុក
  - ការបង្កើតក្រុមប្រឹក្សាឃុំ
- ទ្រឹស្តី និងការអនុវត្តវិមជ្ឈការ និងវិសហមជ្ឈការ
  - និយមន័យពាក្យវិមជ្ឈការ និងវិសហមជ្ឈការ
  - និយមន័យពាក្យ តំណាងប្រជាធិបតេយ្យ ការចូលរួមរបស់ប្រជាពលរដ្ឋ និងគណនេយ្យភាព វិស័យ



សាធារណៈតាមគោលការណ៍កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។

- ច្បាប់រៀបចំអង្គការ
  - ឯកសារផ្លូវការដែលគេធ្វើសេចក្តីព្រាងច្បាប់រៀបចំអង្គការ
  - ភ្នាក់ងារពាក់ពន្ធ័ដែលទទួលខុសត្រូវធ្វើសេចក្តីព្រាងច្បាប់រៀបចំអង្គការ
  - ការសរសេរសេចក្តីព្រាងច្បាប់រៀបចំអង្គការ
  - និយមន័យទីប្រជុំជន/ជនបទក្នុងសេចក្តីព្រាងច្បាប់រៀបចំអង្គការ
- សេវាច្រកចេញចូលតែមួយ
  - ស្រុកគំរូ
  - តួនាទីសេវាច្រកចេញចូលតែមួយ
  - សេវានានាដែលផ្តល់ដោយការិយាល័យច្រកចេញចូលតែមួយ

### *ជំហាន២: ជ្រើសរើសប្រភេទសំណួរនានា*




ជំហានបន្ទាប់នៃការបង្កើតបញ្ជីសំណួរគឺជ្រើសរើសប្រភេទសំណួរនានា ។ គេអាចបែងចែកសំណួរនានាដែលត្រូវបានគេសួរក្នុងការធ្វើតេស្តមុនវគ្គ/ក្រោយវគ្គជាពីផ្នែកធំៗ: សំណួរប្រភេទពិត-មិនពិត សំណួរប្រភេទជ្រើសរើសយកចម្លើយ និងប្រភេទសំណួរបើកដែលមានចម្លើយខ្លី ។

- *សំណួរប្រភេទពិត-មិនពិត:* គេស្នើរឱ្យជ្រើសរើសនូវចម្លើយ សមស្របថាពិតរឺមិនពិត

ដូចឧទាហរណ៍ខាងក្រោមនេះ

ប្រពន្ធ័រដ្ឋបាលមូលដ្ឋាននៅកម្ពុជាបែងចែកជាបីកម្រិត: ខេត្ត/ក្រុង ស្រុក/ខណ្ឌ និងឃុំ/សង្កាត់

| | | | |
|---|---|---|---|
| ពិត | ✓ | មិនពិត | |

- ប្រភេទសំណួរមានចម្លើយជ្រើសរើស: គេស្នើឱ្យរើសនូវចម្លើយដែលសមស្របចេញពីជម្រើស

បីរឺបួន ។ខាងក្រោមនេះគឺជាឧទាហរណ៍

| តើនៅកម្ពុជារៀបចំទឹកដីយ៉ាងដូចម្តេច ? | | |
|---|---|---|
| ក) | រាជធានីភ្នំពេញ ចែកជាខណ្ឌ ខណ្ឌចែកជាសង្កាត់ ខេត្តចែកជាក្រុង និងជាស្រុក ក្រុងចែកជាសង្កាត់ ស្រុកចែកជាឃុំ និងជាសង្កាត់ | ✓ |
| ខ) | រាជធានីភ្នំពេញចែកជាក្រុង ខណ្ឌ និងសង្កាត់ | |
| គ) | ខេត្តចែកជា រាជធានី និងស្រុក រាជធានី និងស្រុកចែកជាឃុំ និងសង្កាត់ | |
| ឃ) | ស្រុកចែកជាឃុំ សង្កាត់ និងខណ្ឌ | |

- សំណួរបើកដែលមានចម្លើយខ្លី ៖គេស្នើឱ្យឆ្លើយដោយពន្យល់ជាសង្ខេប ។ ខាងក្រោមនេះគឺជាឧទាហរណ៍

> ចូរពន្យល់ពីការរៀបចំរចនាសម្ព័ន្ធរដ្ឋបាលនៅកម្ពុជា ?
>
> > រចនាសម្ព័ន្ធរដ្ឋបាលនៅកម្ពុជាបែងចែកជាបីកម្រិត ៖ខេត្ត/ក្រុង ស្រុក/ខណ្ឌ និងឃុំ/សង្កាត ។

### *ជំហាន៣: ការបង្កើតតេស្តមុនវគ្គ និងក្រោយវគ្គ*




យោងតាមលទ្ធផលនៃការធ្វើតេស្តក្នុងំណាក់កាលទីបួន ។ តេស្តមុនវគ្គ/ក្រោយវគ្គនឹងត្រូវបានគេពិនិត្យសម្រេច ។




### *សំណួរដែលល្អ*

សំណួរដែលល្អគឺសាមញ្ញ ខ្លី ច្បាស់លាស់ ហើយត្រូវចំណុចដែលចង់បានដើម្បីជៀសវាងការឆ្លើយភាន់ច្រលំក្នុងការឆ្លើយ ។

### *តេសមុនវគ្គ/ក្រោយវគ្គដែលបង្កើតបានល្អ*

តេស្តមុនវគ្គ/ក្រោយវគ្គដែលល្អគឺងាយស្រួលក្នុងការយល់ និងងាយស្រួលក្នុងការឆ្លើយដែលធ្វើឱ្យអ្នកឆ្លើយចង់បំពេញបញ្ជីសំណួរនោះ ដោយមានការបំពេញខុសឆ្គងតែបន្តិចបន្តួចប៉ុណ្ណោះ ។

### *តេស្តមុនវគ្គ/ក្រោវគ្គ*

យើងមានភ្ជាប់នូវតេស្តមុនវគ្គ/ក្រោយវគ្គក្នុងឧបសម្ពន្ធ័២ ទុកជាឯកសារយោង ។

### *ជំហាន៤: តេស្តមុនវគ្គ/ក្រោយវគ្គ*



ជំហានទីបួនក្នុងការបង្កើតបញ្ជីសំណួរគឺសាកល្បងបញ្ជីសំណួរទាំងនោះ ។ វាជាការប្រសើរណាស់ប្រសិនបើបញ្ជីសំណួរដែលបានរៀបចំនោះ ត្រូវបានគេយកទៅសាកល្បងប្រើជាមួយក្រុមសិក្ខាកាមគំរូនានា ។ ប្រសិនបើមិនអាចទេ សំណួរទាំងនោះអាចយកទៅសាកល្បងជាមួយនឹង ក្រុមមនុស្សដែលមានកម្រិតការងារនោះប្រហាក់ប្រហែលនឹង សិក្ខាកាម ។

ខាងក្រោមនេះគឺជា ចំណុចខ្លះៗដែលត្រូវពិនិត្យពេលសាកល្បង បញ្ជីសំណួរទាំងនោះ

- តើគាត់យល់សំណួរនោះទាំងអស់ទេ?
- ចំពោះសំណួរប្រភេទជ្រើសរើសយកចម្លើយ តើគាត់យល់ពីចម្លើយដែលត្រូវជ្រើសរើសយកទេ?
- តើគាត់មានការលំបាកអ្វីខ្លះក្នុងការឆ្លើយនូវសំណួរទាំងនោះ

### *ជំហាន៥: ពិនិត្យសម្រេចលើតេស្តមុនវគ្គ/ក្រោយវគ្គ*




យោងតាមលទ្ធផលនៃការសាកល្បងបញ្ជីសំណួរក្នុងជំហាន៤ បញ្ជីសំណួរ/សំណួរនឹងត្រូវពិនិត្យសម្រេច ។

ចំពោះទម្រង់បញ្ជីសំណួរគំរូ សូមពិនិត្យមើលឧបសម្ព័ន្ធ ១



ជំហានទាំងប្រាំនៃការបង្កើតការអង្កេតលើផលប៉ះពាល់




ការអង្កេតលើផលប៉ះពាល់អាចធ្វើឡើងជាលក្ខណៈវាយតម្លៃដើម្បីពិនិត្យតាមដានក្នុងរយៈពេលបី រឺបួនខែបន្ទាប់ពីកម្មវិធីបណ្តុះបណ្តាលបានបញ្ចប់ ។ គោលបំណងចម្បងនៃការអង្កេតលើផលប៉ះពាលគឺប៉ាន់ប្រមាណពីការផ្លាស់ប្តូរឥរិយាបទរបស់សិក្ខាកាម (ក្នុងកម្រិត៣) និងពីការរីកចម្រើន រឺក៏លទ្ធផលការងាររបស់ពួកគេដែលទាក់ទងនឹងកម្មវិធីបណ្តុះបណ្តាល (កម្រិត៤)

### *ជំហាន១: កំណត់ថាតើផលប៉ះពាល់អ្វីខ្លះដែលយើងចង់សិក្សា*




ជំហានដំបូងនៃការបង្កើតការអង្កេតលើផលប៉ះពាល់គឺកំណត់ថាតើផលប៉ះពាល់អ្វីខ្លះដែលយើចង់សិក្សា។ ខាងក្រោមនេះគឺជាប្រធានបទសាមញ្ញៗខ្លះដែលគេអាចសួរដល់សិក្ខាកាម

#### *កម្រិត៣: ឥរិយាបទ*

ការវាយតម្លៃក្នុងកម្រិតនេះគឺវាស់វាងថាតើចំណេះដឹង និងជំនាញដែលគេទទួលបានក្នុងការបណ្តុះបណ្តាលបានយកទៅប្រើប្រាស់ក្នុងការងាររបស់គេដែររឺទេ? រយៈពេលដែលត្រូវការក្នុងការផ្លាស់ប្តូរដែលអាចមើលឃើញនោះអាស្រ័យលើប្រភេទនៃការបណ្តុះបណ្តាល ឱកាសឆាប់ប៉ុណ្ណាដែលសិក្ខាកាមបានអនុវត្តជំនាញនោះ រយៈពេលយូរប៉ុណ្ណាដែលសិក្ខាកាមបង្កើតនូវ ទម្រង់ឥរិយាបទថ្មី និងទិដ្ឋភាពផ្សេងៗនៃការងារ ។

#### *កម្រិត៤: លទ្ធផល*



ការវាយតម្លៃក្នុងកម្រិតនេះវាស់វែងពីលទ្ធផលចុងក្រោយដែលកើតឡើងដោយសារតែសិក្ខាកាមបានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាល ។ ឧទាហរណ៍លទ្ធផលចុងក្រោយរួមមាន: ការកើនឡើងផលិតកម្ម ការកើនឡើងគុណភាព និងការថយចុះការចំណាយ

។ជាការសំខាន់ក្នុងការទទួលស្គាល់ថាលទ្ធផលនានានោះគឺបណ្តាលមកពីកម្មវិធីបណ្តុះបណ្តាលខ្លះផងដែរ។ ប៉ុន្តែវាជាការពិបាកក្នុងការបែងចែកផលប៉ះពាល់នៃការបណ្តុះបណ្តាលចេញពីកត្តាដទៃផ្សេងទៀត ដែលជះឥទ្ធិពលដល់លទ្ធផល ។

### *ចដំហានទ២: ការជ្រើសរើសវិធីសាស្ត្រប្រមូលទិន្នន័យ*




វិធីសាស្ត្រដ៏សាមញ្ញបំផុតនៃការប្រមូលទិន្នន័យសម្រាប់ការធ្វើអង្កេតលើផលប៉ះពាល់នោះអាចជាបញ្ជីសំណួរសម្រាប់ការតាមដាន ។ ការសម្ភាសន៍ និង/រឺការពិភាក្សាក្រុមគោលដៅអាចប្រើប្រាស់បានផងដែរ ជាពិសេសពេលដែលគេត្រូវការពត៌មានបែបគុណភាពអំពីផលប៉ះពាល់លើកម្មវិធីបណ្តុះបណ្តាល ។

ការសម្ភាសន៍មានគុណសម្បត្តិខ្លះ និងគុណវិបត្តិខ្លះដែលគួរពិចារណាពេលជ្រើសរើសយកការសម្ភាសន៍ជាវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ ។

*អត្ថប្រយោជន៍នៃការធ្វើសម្ភាសន៍*

- ល្អដើម្បីស្វែងយល់ពីអារម្មណ៍ និងមូលហេតុដែលលាក់លៀមផ្សេងៗ
- ភាសាកាយវិការមួយចំនួនដែលអាចបង្ហាញពីបញ្ហានានា
- អ្វីដែលកើតឡើងដោយឥតព្រាងទុកដែលធ្វើអោយមានបញ្ហាថៃដន្យ

*គុណវិបត្តនៃការធ្វើសម្ភាសន៍*

- ប្រើប្រាស់ពេលវេលា
- មិនមានគំរូច្បាស់លាស់ដែលអាចធ្វើឱ្យមានផលប៉ះពាល់ដល់លទ្ធផល
- ពិបាកក្នុងការគណនាជាតម្លៃ
- ពឹងផ្អែកខ្លាំងលើជំនាញរបស់អ្នកធ្វើសម្ភាសន៍

  មានការសម្ភាសន៍បីប្រភេទដែលអាចប្រើប្រាស់បានសម្រាប់ការសម្ភាសន៍និមួយៗ :

  ១. ការសម្ភាសន៍បែបរចនាសម្ពន្ធ: គេបានត្រៀមសំណួរទុកជាមុន

  ២. ការសម្ភាសន៍បែបពាក់កណ្តាលរចនាសម្ពន្ធ: ជាទូទៅខ្លឹមសារត្រូវបានគេកំណត់ទុកជាមុន ប៉ុន្តែគេអាចបង្កើតសំណួរបន្ថែមទៀត ។ ការធ្វើសម្ភាសន៍បែបនេះសំខាន់ណាស់ក្នុងការសង្កេតពីបញ្ហាគន្លឹះណាមួយ ប៉ុន្តែវាពុំសូវមានភាពប្រាកដទេចំពោះចម្លើយនានាដែលទាក់ទងនឹងបញ្ហាគន្លឹះនោះ ។

៣. ការសម្ភាសន៍បែបគ្មានរចនាសម្ពន្ធ: ធ្វើការសន្ទនាគ្នាដោយសេរីដោយគ្មានបានត្រៀមសំណួរទុកមុនទេ ។

### *ជំហាន៣:ការបង្កើតបញ្ជីសំណួរ/សំណួរ*




ជំហានទីបីនៃការធ្វើអង្កេតលើផលប៉ះពាល់គឺបង្កើតសំណួរនានាដោយយោងលើប្រភេទផលប៉ះពាល់នានាដែលត្រូវស្វែងរក និងវិធីសាស្ត្រប្រមូលទិន្នន័យនានាដែលបានជ្រើសរើស ។




ចូរដាក់ពិន្ទុពី ១-១០ ស្តីពីភាពជាប់ទាក់ទងនៃផ្នែកនិមួយៗទៅនឹងការងាររបស់អ្នក ដោយ (១) បង្ហាញពីភាពគ្មានជាប់ទាក់ទង និង (១០) បង្ហាញពីភាពជាប់ទាក់ទងខ្លាំង

| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|---|
| គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ | | | | | | | | | | ✓ |
| ច្បាប់រៀបចំអង្គការ | | | | | | | | ✓ | | |
| ច្រកចេញចូលតែមួយ | | | | | | ✓ | | | | |

ការប្រើប្រាស់សម្ភារៈបណ្តុះបណ្តាល

តើអ្នកដែលប្រើប្រាស់សម្ភារៈបណ្តុះបណ្តាលទេចាប់ពីអ្នកបានចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលមក?

❑ បាន ❑ មិនបាន

ប្រសិនបើឆ្លើយថា “បាន” ចូរពន្យល់តើសម្ភារៈអ្វីខ្លះដែលអ្នកបានប្រើ ហើយប្រើក្នុងគោលបំណងអ្វី?

______________________________________________

______________________________________________

ការប្រើប្រាស់ចំណេះវិជ្ជា

តើអ្នកបានប្រើប្រាស់នូវចំណេះដឹងជាក់លាក់ណាមួយទាក់ទងនឹងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងច្បាប់រៀបចំអង្គការដែរឬទេ បន្ទាប់ពីទទួលបានការបណ្តុះបណ្តាល?

❑ បាន ❑ ទេ

ប្រសិនបើឆ្លើយ បាន ចូរពន្យល់ថាតើចំណេះដឹងអ្វីខ្លះ ហើយបានប្រើប្រាស់ដោយរបៀបណា?

________________________________________________
________________________________________________
________________________________________________

ខាងក្រោមនេះគឺជាសំណួរដែលប្រើក្នុងការសម្ភាសន៍ខ្លះៗក្នុងការធ្វើ អង្កេតពីផលប៉ះពាល់ដែលធ្វើឡើងក្នុងខែមិថុនា ឆ្នាំ ២០០៨ ។ចំពោះ ព័ត៌មានលម្អិត សូមពិនិត្យមើលឧបសម្ព័ន្ធ៣ ស្តីពីសំណួរដែលប្រើក្នុងការធ្វើអង្កេត

១. តើអ្នកបានប្រើប្រាស់ជំនាញ និងចំណេះដឹងដែលទាក់ទងនឹងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងច្បាប់រៀបចំអង្គការដែរឬទេ បន្ទាប់ពីទទួលបានការបណ្តុះបណ្តាល ?
២. តើអ្នកមានបានប្រើប្រាស់ឯកសារទាំងនោះទេ បន្ទាប់ពីអ្នកបានចូលរួមវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលា?
៣. តើអ្នកមានបានប្រើប្រាស់នូវអ្វីដែលអ្នកបានរៀនក្នុងវគ្គបណ្តុះបណ្តាល/សិក្ខាសាលាក្នុងកិច្ចការរបស់អ្នកដែរឬទេ?
៤. ជាលទ្ធផលនៃការបណ្តុះបណ្តាលឬសិក្ខាសាលា តើអ្នកមានបានផ្លាស់ប្តូរនូវការយល់ឃើញ អត្តចរិក ឬឥរិយាបទណាមួយទេ ?

***ជំហាន៤: ធ្វើតេស្តសាកល្បងបញ្ជីសំណួរ***

ជំហាន ១: កំណត់ពីអ្វីដែលយើងចង់រក → ជំហាន ២: ជ្រើសរើសវិធីសាស្ត្រប្រមូលទិន្នន័យ → ជំហាន ៣: បង្កើតបញ្ជីសំណួរ → ជំហាន ៤: ធ្វើតេស្តសាកល្បងបញ្ជីសំណួរ → ជំហាន ៥: ពិនិត្យសម្រេចលើបញ្ជីសំណួរ/សំណួរ

ជំហានទីបួនក្នុងការបង្កើតបញ្ជីសំណួរគឺសាកល្បងបញ្ជីសំណួរទាំងនោះ ។ វាជាការប្រសើរណាស់ប្រសិនបើបញ្ជីសំណួរដែលបានរៀបចំនោះ ត្រូវបានគេយកទៅសាកល្បងប្រើជាមួយក្រុមសិក្ខាកាមគំរូនានា ។ ប្រសិនបើមិនអាចទេ សំណួរទាំងនោះអាចយកទៅសាកល្បងជាមួយនឹង ក្រុមមនុស្សដែលមានកម្រិតការងារនោះប្រហាក់ប្រហែលនឹង សិក្ខាកាម ។

ខាងក្រោមនេះគឺជា ចំណុចខ្លះៗដែលត្រូវពិនិត្យពេលសាកល្បង បញ្ជីសំណួរទាំងនោះ

- តើគាត់យល់សំណួរនោះទាំងអស់រឺទេ?
- តើគាត់មានការលំបាកអ្វីខ្លះក្នុងការឆ្លើយនូវសំណួរទាំងនោះ ?
- តើគ្រប់សំណួរបិទទាំងអស់មានចម្លើយដែលទាក់ទងនឹងចម្លើយនិមួយៗដែររឺទេ?
- តើការរំលងសំណួរមួយទៅសំណួរផ្សេងទៀតត្រូវបានគេធ្វើឡើងត្រឹមត្រូវដែររឺទេ?
- តើមានផ្នែកណាមួយដែលលើកឡើងនោះមានភាពផ្ទុយគ្នាដែររឺទេ?
- តើសំណួរដែលបានបង្កើតឡើងនោះផ្តល់នូវចំណាប់អារម្មណ៍ជាវិជ្ជមានសម្រាប់អ្នកឆ្លើយដែររឺទេ?



### *ជំហាន៥: ការពិនិត្យសម្រេចលើបញ្ជីសំណួរ*




យោងតាមលទ្ធផលនៃការសាកល្បងបញ្ជីសំណួរក្នុងជំហាន៤ បញ្ជីសំណួរ/សំណួរនឹងត្រូវពិនិត្យសម្រេច។

**ឯកសារយោង:**


- "Chapter 9 Collecting Data: Application and Business Impact Evaluation" (p.136-p.164) *Handbook of Training Evaluation and Measurement Methods.*
- "7. Questionnaire Design" (p.101-p.135) *How to Conduct Your Own Survey.*
- "Part Two: Case Studies of Implementation" (p.117-p.360) *Evaluating*

# ៥ ជំហាន ៤:ប្រមូលទិន្នន័យ




## បញ្ជីសំណួរ

ខាងក្រោមនេះគឺជាការណែនាំដែលមានប្រយោជន៍ខ្លះៗដើម្បីបង្កើនប្រសិទ្ធភាពនៃប្រមូលទិន្នន័យ ។



### សរសេចម្លើយដោយមិនដាក់ឈ្មោះ

ប្រសិនបើមានមូលហេតុជាក់លាក់ដែលអ្នកចង់បង្ហាញបញ្ជីសំណួរនិមួយៗដល់សិក្ខាកាម សូមឱ្យគេឆ្លើយដោយមិនដាក់ឈ្មោះ ។ វាធ្វើឱ្យសិក្ខាកាមមានអារម្មណ៍បើកទូលាយ និងស្រួលក្នុងការបញ្ចេញមតិនានាដែលមានប្រយោជន៍ដើម្បីកែលម្អកម្មវិធីបណ្តុះបណ្តាល។

### ចែកទម្រង់បញ្ជីសំណួរមុន

ចំពោះការវាយតម្លៃដែលមានរយៈពេលយូរលើកម្មវិធីបណ្តុះបណ្តាលដែលមានរយៈពេលច្រើនថ្ងៃ រឺក៏អ្នកចង់ឱ្យសិក្ខាកាមវាយតម្លៃលើផ្នែកនិមួយៗ ជាការប្រសើរគួរចែកបញ្ជីសំណួរជូនជាមុន ដែលធ្វើឱ្យសិក្ខាកាមយល់កាន់តែច្បាស់ពីសំណួរដែលត្រូវឆ្លើយក្នុងវគ្គបណ្តុះបណ្តាល ។ ប៉ុន្តែសូមប្រយត្ន័ថា សិក្ខាកាមគួរតែរងចាំរហូតដល់ដំណាក់កាលចុងក្រោយនៃកម្មវិធី ទើបធ្វើការវាយតម្លៃជារួម ហេតុនេះសំណួរសម្រាប់វាយតម្លៃជារួមអាចចែកជូននៅពេលចុងបញ្ចប់នៃកម្មវិធី ។

### ពន្យល់ពីគោលបំណងនៃបញ្ជីសំណួរ និងថាតើព័ត៌មានទាំងនោះត្រូវបានគេប្រើប្រាស់ដោយរបៀបណា

គោលបំណងនៃបញ្ជីសំណួរ និងពីរបៀបដែលទិន្នន័យទាំងអស់ត្រូវបានគេប្រើប្រាស់គួរតែពន្យល់ឱ្យបានច្បាស់លាស់ដល់សិក្ខាកាម ។ វានឹងជួយនូវអត្រានៃការឆ្លើយ និងលើកទឹកចិត្តដល់សិក្ខាកាមផ្តល់អនុសាសន៍ផ្សេងៗ ដើម្បីកែលម្អកម្មវិធីនាពេលអនាគត ។

*ផ្តល់ពេលវេលាគ្រប់គ្រាន់ដើម្បីបំពេញបញ្ជីសំណួរ*

ប្រសិនបើយើងស្នើឱ្យសិក្ខាកាមបំពេញសំណួរនៅចុងបញ្ចប់នៃកម្មវិធី ពួកគេអាចប្រញាប់ប្រញាល់ចាកចេញ រឺក៏បំពេញសំណួរដោយរំលង ។ សូមបែងចែកពេលវេលាគ្រប់គ្រាន់ក្នុងការបំពេញសំណួរទាំងនោះតាមកាលវិភាគ មុននឹងបញ្ចប់កម្មវិធី ។

**តេស្តមុនវគ្គ/ក្រោយវគ្គ**

សំណួរដូចគ្នាដែលបានរៀបចំក្នុងជំហាន៣ នឹងត្រូវបានគេផ្តល់ជូនសិក្ខាកាមនៅថ្ងៃទីមួយនៃការបណ្តុះបណ្តាលមុននឹងចាប់ៗ (តេស្តមុនវគ្គ) និងនៅថ្ងៃចុងក្រោយបន្ទាប់ពីបានបញ្ចប់ផ្នែកផ្សេងៗមក (តេស្តចុងក្រោយ) ។



**តេស្តមុនវគ្គ**

ថ្ងៃទីមួយនៃវគ្គបណ្តុះបណ្តាល

មុនផ្នែកនានាទាំងអស់



**ផ្នែកនានា**



**តេស្តក្រោយវគ្គ**

ថ្ងៃចុងក្រោយនៃវគ្គ

បន្ទាប់ពីផ្នែកនានាទាំងអស់

## ការសម្ភាសន៍បែបពាក់កណ្តាលរចនាសម្ព័ន្ធ

ខាងក្រោមនេះគឺជាការណែនាំខ្លះៗទាក់ទងនឹងការធ្វើសម្ភាសន៍ប្រកបដោយប្រសិទ្ធភាព

### សេចក្តីផ្តើម

- [ការថ្លែងអំណរគុណ] សូមថ្លងអំណរគុណយ៉ាងជ្រាលជ្រៅក្នុងការសម្ភាសន៍
- [ណែនាំខ្លួន] ខ្ញុំឈ្មោះ.................មកពីក្រសួងមហាផ្ទៃនៃ អ.រ.ម
- គោលបំណងនៃការសម្ភាសន៍ ខ្ញុំសូមសួរលោក/លោកស្រីនូវសំណួរមួយចំនួនអំពីវគ្គបណ្តុះបណ្តាល/សិក្ខាសាលាដែលអ្នកបានចូលរួមនៅឆ្នាំមុន ។ ព័ត៌ដែលលោក/លោកស្រីផ្តល់ជូននឹងត្រូវបានប្រើប្រាស់ដើម្បីកែលម្អកម្មវិធីបណ្តុះបណ្តាលនាពេលអនាគត ។

### ឥរិយាបទវិជ្ជមាន

- **មើលមុខអ្នកដែលយើងសម្ភាសន៍**
  - អ្នកដែលត្រូវយើងសម្ភាសន៍ដឹងថាយើងកំពុងតែផ្តោតការយកចិត្តទុកដាក់ចំពោះគាត់
  - អ្នកដែលយើងសម្ភាសន៍មានអារម្មណ៍ថាអាចទទួលយកបាន
  - អង្គុយត្រង់ខ្លួន សូមកុំពន្ធ័ដៃ រឺជើង

- **ញញឹម ដោយរាក់ទាក់**
  - អ្នកដែលយើងត្រូវសម្ភាសន៍មានអារម្មណ៍ស្រួលចិត្ត ព្រមទាំងងាយនិយាយ
  - អ្នកដែលយើងសម្ភាសន៍នឹងមានចិត្តផ្តល់នូវព័ត៌មានបន្ថែម

- **ផ្តល់នូវព័ត៌មានត្រលប់វិជ្ជមាន**
  - អ្នកដែលយើងសម្ភាសន៍មានអារម្មណ៍ថាព័ត៌មានដែលគាត់ផ្តល់ឱ្យមានសារៈសំខាន់
  - អ្នកដែលយើងសម្ភាសន៍មានចិត្តចង់ផ្តល់ព័ត៌មាន
  - ប្រើក្រសែភ្នែក និយាយនូវចម្លើយឡើងវិញ ដោយដោយប្រើឃ្លាសារដើម

### វិធីនានាដើម្បីទទួលបានចម្លើយចំពោះសំណួរបើក

- ពេលដែលអ្នកមិនយល់នូវចម្លើយរបស់អ្នកដែលលោកអ្នកសម្ភាសន៍

- “តើអ្នកមានន័យយ៉ាងដូចម្តេច ?”
- “តើអ្នកចង់មានន័យថាយ៉ាងដូចម្តេច”
- “តើអ្នកអាចប្រាប់ខ្ញុំបន្ថែមទៀតបានទេអំពីទស្សនៈរបស់អ្នកលើចំណុចនោះ?”

● ពេលដែលអ្នកចង់ដឹងនូវចម្លើយបន្ថែមទៀតៈ

- “តើអ្នកអាចពន្យល់បន្ថែមទៀតបានទេចំពោះចំណុចនេះ”
- “អ្វី?” “អ្នកណា?” “ពេលណា?” “កន្លែងណា?” “ដោយរបៀបណា?”

# ៦ ជំហាន៥: វិភាគ និងរាយការណ៍ពីលទ្ធផលនានា




## ការបញ្ចូលទិន្នន័យ

ទិន្នន័យទាំងអស់ត្រូវបញ្ចូលក្នុងកុំព្យូទ័រ មុននឹងសរុបវិភាគលើបញ្ជីសំណួរ រឺទិន្នន័យមុនវគ្គ និងក្រោយវគ្គដែលប្រមូលបានក្នុងជំហាន៤ ។ មានកម្មវិធី software ផ្នែកស្ថិតិច្រើន ។ កម្មវិធីសាមញ្ញដូចជា MS Excel គឺអាចប្រើប្រាស់បានសមរម្យហើយ លើកលែងតែអ្នកត្រូវការមានទម្រង់ទិន្នន័យដែលធំសម្បើម រឺ ក៏អ្នកត្រូវការធ្វើការវិភាគកម្រិតខ្ពស់ ។ តារាងទិន្នន័យគំរូមានភ្ជាប់ក្នុងឧបសម្ពន្ធ៤ ជាឯកសារយោង៖

## ការវិភាគទិន្នន័យ

មានវិធីច្រើនក្នុងការវិភាគទិន្នន័យ ប៉ុន្តែការវិភាគគួរតែមានលក្ខណៈសាមញ្ញតាមដែលអាចធ្វើទៅបាន ដែលអាចកំណត់បានពីការធ្វើសេចក្តីសន្និដ្ឋានលើការការវិភាគ ។

### *របាយប្រេកង់ និងមធ្យម*

ការបែងចែកប្រេកង់ និងធម្យមភាគមានវិធីសាមញ្ញពីរយ៉ាងក្នុងការបង្ហាញទិន្នន័យ ។

ខាងក្រោមនេះគឺជាឧទាហរណ៍ខ្លះៗនៃរបាយប្រេកង់ និងមធ្យមភាគនៃការវាយតម្លៃលើផ្នែកនិមួយៗ ដំណើរការ វិត្តនីវិមជ្ឈការ និងវិសហមជ្ឈការ ក្នុងសិក្ខាសាលាមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្នុងខែ កក្កដា ឆ្នាំ ២០០៧ ។

| ដំណើរការវិវត្ត D & D | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|
| ខ្លឹមសារ | 0 | 0 | 0 | 0 | 3 | 2 | 10 | 23 | 63 | 127 | 228 |
| សម្ភារ: | 0 | 0 | 2 | 2 | 1 | 6 | 14 | 33 | 57 | 115 | 230 |
| កម្រិតយល់ដឹង | 0 | 0 | 0 | 1 | 5 | 6 | 33 | 62 | 65 | 56 | 228 |

| ដំណើរការវិវត្ត D & D | | មធ្យមភាគ |
|---|---|---|
| ខ្លឹមសារ | | 9.29 |
| សម្ភារៈ | | 9.04 |
| កម្រិតយល់ដឹង | | 8.50 |
| | សរុប | 8.94 |

### *ការប្រើប្រាស់គំនូសតាងដើម្បីបង្ហាញទិន្នន័យ*

គំនូសតាងគឺជាឧបករណ៍ដ៏មានសារៈសំខាន់ក្នុងការបង្ហាញទិន្នន័យស្ថិតិ និងទិន្នន័យដែលមានលក្ខណៈស្មុគស្មាញបានយ៉ាងសាមញ្ញ រហ័ស និងងាយស្រួល ។ គំនូសតាងទាំងនោះមានច្រើនប្រភេទ រួមមាន Chart, graph និង illustration ។ Chart មានរាងជារង្វង់ និង Chart មានរាងជាសសរ ត្រូវបានគេប្រើប្រាស់ជាទូទៅ ។

.




Source: Top Management Seminar Implementation Report, GDLA Task Force, October 2007

Chart រាងជាសសរបង្ហាញលទ្ធផលបានល្អប្រសើរជាងពេលដែលមានទិន្នន័យច្រើនប្រភេទត្រូវប្រៀបធៀប និងដើម្បីបង្ហាញពីទំនាក់ទំនងសំខាន់នានា ។ ខាងក្រោមនេះគឺជាឧទាហរណ៍ទាក់ទងនឹង chart រាងជាសសរដែលបង្ហាញពីរបាយពិន្ទុ តេស្តមុនវគ្គ និងក្រោយវគ្គនៃការបណ្តុះបណ្តាលមន្ត្រី អ.រ.ម ក្នុងខែកក្កដា ឆ្នាំ ២០០៧ ។




Source: GDLA Officials Training Implementation Report, GDLA Task Force, October 2007

## ការធ្វើរបាយការណ៍

### តើនរណាត្រូវដឹងអ្វីខ្លះ ?

មុននឹងសរសេររបាយការណ៍វាយតម្លៃ យើងត្រូវបង្ហាញថានរណាជាអ្នកដំបូងដែលត្រូវប្រើប្រាស់ការវាយតម្លៃ ។អ្នកដែលត្រូវប្រើប្រាស់ដំបូងជាបុគ្គលជាក់លាក់នានា រឺអង្គភាពដែលព័ត៌មានរបស់អ្នកទាំងនោះត្រូវការអ្នកផ្តល់ជូនគេ ។ ពួកគេអាចជា នាយកកម្មវិធី ភ្នាក់ងារផ្តល់មូលនិធិ អ្នកធ្វើសេចក្តីសម្រេចចិត្តកម្មវិធី រឺអ្នកធ្វើគោលនយោបាយ ។អ្នកដែលប្រើប្រាស់ដំបូងដូចជា នាយកកម្មវិធីនានា និងភ្នាក់ងារផ្តល់ជំនួយនានាជាទូទៅត្រូវការនូវព័ត៌មានបច្ចេកទេស និងព័ត៌មានលម្អិត ព្រោះពួកគេធ្វើសេចក្តីសម្រេចចិត្តសំខាន់ទាក់ទងនឹងកម្មវិធីបណ្តុះបណ្តាលនានា ។



### *ទម្រង់នៃលទ្ធផលទំនាក់ទំនងការវាយតម្លៃ*

ជំហានបន្ទាប់គឺកំណត់ថាតើទម្រង់នៃការទំនាក់ទំនងអ្វីខ្លះដែលមានប្រសិទ្ធិភាពបំផុតក្នុងការបង្ហាញនូវលទ្ធផលនៃការវាយតម្លៃជូនដល់អ្នកប្រើប្រាស់បឋមនានា ។គេអាចប្រើប្រាស់នូវសំណួរខាងក្រោមនេះជាប្រទីបដើម្បីជ្រើសរើសពីទម្រង់ទំនាក់ទំនងដែលត្រឹមត្រូវ ៖

- តើព័ត៌មានពាក់ព័ន្ធនឹងបញ្ហាជាក់ស្តែងរបស់អ្នកប្រើប្រាស់ត្រង់ចំណុចណាខ្លះ និងក្នុងលក្ខខណ្ឌណាខ្លះ ?
- តើក្នុងវិសាលភាពណាខ្លះដែលព័ត៌មានអាចអនុវត្តបានចំពោះអ្នកប្រើប្រាស់នាពេល អនាគត?
- តើក្នុងវិសាលភាពណាខ្លះ ដែលព័ត៌មានមានសារៈសំខាន់ និងអាចប្រើប្រាស់បានភ្លាមៗក្នុងស្ថានភាពរបស់អ្នកប្រើប្រាស់ ?
- តើពត៌មានអ្វីខ្លះដែលអ្នកប្រើប្រាស់គិតថាអាចជឿជាក់បាន ហើយថាតើរបាយការណ៍អនុវត្តអ្វីខ្លះដែលបញ្ជាក់ឱ្យមានការជឿជាក់នោះ?
- *Source: Morris, Lynn Lyons et al. (1987). How to Communicate Evaluation Findings. SAGE Publications.*

### *គោលសង្ខេបលើរបាយការណ៍ការវាយតម្លៃ*

បន្ទាប់ពីបានដឹងថាតើព័ត៌មានអ្វីខ្លះ ដែលពាក់ព័ន្ធ និងមានសារៈសំខាន់ចំពោះអ្នកប្រើប្រាស់បឋមនោះ ។ អ្នកអាចបង្កើតគោលសង្ខេបនៃរបាយការណ៍វាយតម្លៃមួយ ។ ខាងក្រោមនេះគឺជាឧទាហរណ៍ ៖

**សេចក្តីសង្ខេប**

- គោលបំណងនៃការវាយតម្លៃ
- អ្នកស្តាប់របាយការណ៍វាយតម្លៃ
- លទ្ធផលចម្បងៗ និងអនុសាសន៍នានា

**ការអធិប្បាយពីកម្មវិធី**

- សាវតាកម្មវិធី
- គោលដៅ/គោលបំណងកម្មវិធី
- អ្នកពាក់ព័ន្ធនានារបស់កម្មវិធី

- សកម្មភាពនានា

**ការបង្កើតការវាយតម្លៃ និងវិធីសាស្ត្រនានា**

- គោលបំណងនៃការវាយតម្លៃ
- ការបង្កើតការវាយតម្លៃ
- វិធីសាស្ត្រប្រមូលទិន្នន័យ

**ការរកឃើញ និងលទ្ធផលនានា**

- ការរៀបរាប់ពីរបៀបនៃការរៀបចំនូវការរកឃើញនានា (ឧ. តាមការវាយតម្លៃសំណួរ រឺបញ្ហានានា ។ល ។)
- លទ្ធផលនានានៃការវិភាគលើទិន្នន័យបែបគុណភាព រឺបែបបរិមាណនានាដែលប្រមូលបាន

**អនុសាសន៍**

- អនុសាសន៍នានាដើម្បីចាត់វិធានការណ៍យោងតាមសេចក្ដីសន្និដ្ឋាន

**ឧបសម្ព័ន្ធ**

- បញ្ជីឈ្មោះសិក្ខាកាម
- សម្ភារៈបណ្ដុះបណ្ដាល/សិក្ខាសាលា
- បញ្ជីសំណួរ តេស្តមុនវគ្គ/ក្រោយវគ្គ
- ចំណាយសរុបលើកម្មវិធី

**ឯកសារយោង:**

- "Chapter 14 Data Analysis" (p.237-p.254), "Chapter 19 Communicating Program Results" (p.337-p.359) *Handbook of Training Evaluation and Measurement Methods.*
- "8. Analyzing Evaluation Data" (p.267-p.308), "9. Communicating and Reporting Evaluation Processes and Findings" (p.309-p.326) *Building Evaluation Capacity.*
- "9. From Questionnaires to Survey Results" (p.175-p.200), "10. Reporting Survey Results" (p.201-p.214) *How to Conduct Your Own Survey.*
- "4. Selecting Commonly Used Statistical Methods for Surveys" (p.77-p.121) *How to Manage, Analyze, and Interpret Survey Data.*
- *How to Communicate Evaluation Findings.*
- *Evaluation Strategies for Communicating and Reporting.*

**ឧបសម្ព័ន្ធ ១**

# ឧម្រង់បញ្ជីសំណួរគំរូ

សិក្ខាសាលាមន្ត្រីរដ្ឋបាលជាន់ខ្ពស់

## ការវាយតម្លៃវគ្គបណ្តុះបណ្តាល (សំរាប់ថ្ងៃទីមួយ)

| | ១. ខ្លឹមសារ តើលោកអ្នកយល់យ៉ាងណាចំពោះខ្លឹមសារមេរៀន? | | | | | | | | | | ២. ឯកសារ និង សម្ភារៈ [illegible] | | | | | | | | | | ៣. ការចូលរួមរបស់សិក្ខាកាម [illegible] | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | មិនល្អ | | | | | | | | | ល្អ | មិនល្អ | | | | | | | | | ល្អ | មិនល្អ | | | | | | | | | ល្អ |
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| Session 2 [illegible] | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| Session 3 [illegible] | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| Session 4 [illegible] | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| Session 5 [illegible] | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

មតិយោបល់

.....................................................................................................................

.....................................................................................................................

## ការវាយតម្លៃវគ្គបណ្តុះបណ្តាល (សំរាប់ថ្ងៃទីពីរ)

| | ១. ខ្លឹមសារ [illegible] | | | | | | | | | | ២. ឯកសារ និង សម្ភារៈ [illegible] | | | | | | | | | | ៣. ការចូលរួមរបស់សិក្ខាកាម [illegible] | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | មិនល្អ | | | | | | | | | ល្អ | មិនល្អ | | | | | | | | | ល្អ | មិនល្អ | | | | | | | | | ល្អ |
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| Session 10 [illegible] | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| Session 11 [illegible] | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

មតិយោបល់

.....................................................................................................................

.....................................................................................................................

## ការវាយតម្លៃវគ្គបណ្តុះបណ្តាល (ការវាយតម្លៃសរុប)

| ១. [illegible] [illegible] | | | | | | | | | | ២. [illegible] [illegible] | | | | | | | | | | ៣. [illegible] [illegible] | | | | | | | | | | ៤. [illegible] [illegible] | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| មិនល្អ | | | | | | | | | ល្អ | មិនល្អ | | | | | | | | | ល្អ | មិនល្អ | | | | | | | | | ល្អ | មិនល្អ | | | | | | | | | ល្អ |
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

មតិយោបល់ ……………………………… មតិយោបល់ ……………………………… មតិយោបល់ ……………………………… មតិយោបល់ ………………………………

……………………………………………………………………………………………………

……………………………………………………………………………………………………

សូមគូស session ណាមួយដែលអ្នកពេញចិត្តជាងគេ (សូមជ្រើសរើសចម្លើយតែមួយ)

| | | |
|---|---|---|
| ថ្ងៃទី ១ | Session 2: វឌ្ឍនភាព នៃគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ | |
| | Session 3: ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ | |
| | Session 4: ប្រព័ន្ធរដ្ឋបាលមូលដ្ឋានប្រទេសជប៉ុន | |
| | Session 5: ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនៅប្រទេសជប៉ុន | |
| ថ្ងៃទី ២ | Session 10: ករណីសិក្សា: ការិយាល័យច្រកចេញចូលតែមួយ | |
| | Session 11: គណនេយ្យភាពនិងសេវាសាធារណៈនៃប្រព័ន្ធវិមជ្ឈការនៅកម្ពុជា | |

សូមពន្យល់ពីមូលហេតុដែលលោកអ្នកពេញចិត្ត session នោះជាងគេ

……………………………………………………

……………………………………………………

……………………………………………………

……………………………………………………

……………………………………………………

……………………………………………………

ឧបសម្ព័ន្ធ ២

ទម្រង់គំរូ តេស្តមុនវគ្គ/ក្រោយវគ្គ (វគ្គបណ្តុះបណ្តាលមន្ត្រី អ.វ.ម)

## ចម្លើយតេស្តមុន /ក្រោយវគ្គ

## វគ្គបណ្តុះបណ្តាលមន្ត្រី អ.វ.ម

ការវាយតម្លៃនេះមានសំណួរ២០ ដែលពាក់ព័ន្ធនឹងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលមូលដ្ឋាននៅកម្ពុជា និងជប៉ុន គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ទស្សនៈទានសំខាន់ៗនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងថ្នាក់រដ្ឋបាល ថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និងការិយាល័យច្រកចេញចូលតែមួយ ។ សំណួរនីមួយៗ មានចម្លើយ ៤ ដែលត្រូវជ្រើសរើស ។ សូមជ្រើសរើសយកចម្លើយមួយ ដែលអ្នកយល់ថាត្រឹមត្រូវជាងគេ ។

### SESSION 3 : ប្រព័ន្ធរដ្ឋបាលមូលដ្ឋាន នៅប្រទេសកម្ពុជា និងជប៉ុន

| | | |
|---|---|---|
| **១-** | **តើនៅប្រទេសកម្ពុជាគេរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងអាជ្ញាធរមូលដ្ឋានយ៉ាងដូចម្តេច ?** | |
| ក) | ប្រព័ន្ធអាជ្ញាធរមូលដ្ឋាននៅកម្ពុជាចែកជា៣ថ្នាក់ : ថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ។ | ✓ |
| ខ) | ប្រព័ន្ធអាជ្ញាធរមូលដ្ឋាននៅកម្ពុជាចែកជា២ថ្នាក់ : ថ្នាក់ខេត្ត ក្រុង និងស្រុក ខណ្ឌ ។ | |
| គ) | ប្រព័ន្ធអាជ្ញាធរមូលដ្ឋាននៅកម្ពុជាចែកជា៤ថ្នាក់ : ថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងភូមិ ។ | |
| ឃ) | ប្រព័ន្ធអាជ្ញាធរមូលដ្ឋាននៅកម្ពុជាតាមផ្លូវច្បាប់មិនបានបែងចែកជាថ្នាក់ផ្សេងៗឡើយ ។ | |
| **២-** | **តើមុខងារណាមួយខាងក្រោមនេះ ជាមុខងាររបស់រដ្ឋបាលថ្នាក់ខេត្ត ក្រុង?** | |
| ក) | រៀបចំផែនការអភិវឌ្ឍឃុំ | |
| ខ) | តែងតាំងមេភូមិ | |
| គ) | ការចុះបញ្ជីអត្រានុកូលដ្ឋាន | |
| ឃ) | លើកកម្មវិធីអភិវឌ្ឍរបស់ខេត្ត ក្រុង | ✓ |
| **៣-** | **តើមុខងារណាមួយខាងក្រោមនេះ ជាមុខងាររដ្ឋបាលថ្នាក់ស្រុក ខណ្ឌ?** | |
| ក) | ការពារមតិកវប្បធម៌ និងបរិស្ថានធម្មជាតិ ។ | |
| ខ) | ទទួលបន្ទុកចម្លងលិខិតអត្រានុកូលដ្ឋាន និងរក្សាសៀវភៅអត្រានុកូលដ្ឋានឆ្នាំចាស់ | ✓ |
| គ) | រាយការណ៍ទៅរដ្ឋាភិបាលកណ្តាល | |
| ឃ) | ចេញលិខិតអនុញ្ញាតឱ្យធ្វើពាណិជ្ជកម្ម អាជីវកម្មផ្សេងៗ | |

| ៤- តើប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានជ្រើសរើសដោយរបៀបណា ? | |
|---|---|
| ក) តែងតាំងដោយក្រសួងមហាផ្ទៃ | |
| ខ) បោះឆ្នោតដោយប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់? | |
| គ) ជ្រើសរើសដោយមេភូមិ នៅក្នុងឃុំ សង្កាត់ ។ | |
| ឃ) ត្រូវជ្រើសរើសចេញពីបេក្ខជនលេខរៀងលើគេបង្អស់នៃបញ្ជីបេក្ខជនដែលបានទទួលសម្លេងឆ្នោតច្រើនជាងគេ | ✓ |
| **៥- តើក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ មានសមាជិកក្រុមប្រឹក្សាប៉ុន្មាននាក់ ?** | |
| ក) ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ មានសមាជិកក្រុមប្រឹក្សា៨នាក់ ។ | |
| ខ) ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ មានសមាជិកក្រុមប្រឹក្សា១១នាក់ | |
| គ) ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ មានសមាជិកក្រុមប្រឹក្សាពី៨ទៅ១២នាក់ ដោយផ្អែកតាមប្រជាសាស្ត្រ និភូមិសាស្ត្រ | |
| ឃ) ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗមានសមាជិកក្រុមប្រឹក្សាពី៥ទៅ១១នាក់ ដោយផ្អែកតាមប្រជាសាស្ត្រ និងភូមិសាស្ត្រ | ✓ |

## SESSION 4: ទ្រឹស្តី និងការអនុវត្ត គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ

| ៦. តើអ្វីទៅជាវិមជ្ឈការ ? | |
|---|---|
| ក) ដើម្បីផ្ទេរអំណាច និងការទទួលខុសត្រូវពីរដ្ឋបាលថ្នាក់កណ្តាលឱ្យទៅអាជ្ញាធរមូលដ្ឋានដើម្បីគ្រប់គ្រង និងម្ចាស់ការ ដោយខ្លួនឯង ព្រមទាំងភ្ជាប់ជាមួយនូវធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិកផ្ទាល់ខ្លួនដោយឡែក ។ | ✓ |
| ខ) ដើម្បីផ្ទេរអំណាច និងការទទួលខុសត្រូវពីរដ្ឋបាលថ្នាក់កណ្តាលឱ្យទៅក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីគ្រប់គ្រង និងម្ចាស់ការដោយខ្លួនឯង ព្រមទាំងភ្ជាប់ជាមួយនូវធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិកផ្ទាល់ខ្លួនដោយឡែក ។ | |
| គ) ជាការចែករំលែកអំណាចរបស់រដ្ឋបាលកណ្តាលដល់រដ្ឋបាលមូលដ្ឋាន ( អាជ្ញាធរមូលដ្ឋាន ការិយាល័យ មន្ទីរ) ក្នុងការអនុវត្តនូវអំណាច ឬមុខងារក្នុងនាមខ្លួនជារដ្ឋបាលកណ្តាល ដោយផ្តល់នូវធនធាន ឬកម្រៃសេវា និងការបង្កើន សមត្ថភាព ហើយរដ្ឋបាលមូលដ្ឋានទទួលខុសត្រូវចំពោះរដ្ឋបាលកណ្តាល ចំណែករដ្ឋបាលកណ្តាលនៅតែទទួលត្រូវ ជាចុងក្រោយចំពោះមុខច្បាប់ ។ | |

| | |
|---|---|
| ឃ) ជាការចែករំលែកអំណាចរបស់រដ្ឋបាលកណ្តាលដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការអនុវត្ត នូវអំណាចឬមុខងារខ្លួនជារដ្ឋបាលកណ្តាលដោយផ្តល់នូវធនធាន ឬកម្រៃសេវា និងការបង្កើនសមត្ថភាព ហើយរដ្ឋបាល មូលដ្ឋានទទួលខុសត្រូវចំពោះរដ្ឋបាលកណ្តាលចំណែករដ្ឋបាលកណ្តាលនៅតែទទួលខុសត្រូវជាចុងក្រោយចំពោះមុខច្បាប់ ។ | |

| **៧. តើអ្វីទៅជាវិសហមជ្ឈការ ?** | |
|---|---|
| ក) ដើម្បីផ្ទេរអំណាច និងការទទួលខុសត្រូវពីរដ្ឋបាលថ្នាក់កណ្តាលឱ្យទៅអជ្ញាធរមូលដ្ឋាន ដើម្បីគ្រប់គ្រង និងម្ចាស់ការដោយខ្លួនឯង ព្រមទាំងភ្ជាប់ជាមួយនូវធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ និងបុគ្គលិកផ្ទាល់ខ្លួន ដោយឡែក ។ | |
| ខ) ដើម្បីផ្ទេរអំណាច និងការទទួលខុសត្រូវពីរដ្ឋបាលថ្នាក់កណ្តាលឱ្យទៅក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីគ្រប់គ្រង និងម្ចាស់ការដោយខ្លួនឯង ព្រមទាំងភ្ជាប់ជាមួយនូវធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិនិងបុគ្គលិកផ្ទាល់ខ្លួនដោយឡែក ។ | |
| គ) ជាការចែករំលែកអំណាចរបស់រដ្ឋបាលកណ្តាលដល់រដ្ឋបាលមូលដ្ឋាន (អជ្ញាធរមូលដ្ឋាន ការិយាល័យមន្ទីរ) ក្នុងការអនុវត្ត នូវអំណាច ឬមុខងារក្នុងនាមខ្លួនជារដ្ឋបាលកណ្តាល ដោយផ្តល់នូវធនធាន ឬកម្រៃសេវានិងការបង្កើនសមត្ថភាព ហើយរដ្ឋបាលមូលដ្ឋានទទួលខុសត្រូវចំពោះរដ្ឋបាលកណ្តាល ចំណែករដ្ឋបាលកណ្តាល នៅតែទទួលខុសត្រូវជាចុង ក្រោយចំពោះមុខច្បាប់ ។ | ✓ |
| ឃ) ជាការចែករំលែកអំណាចរបស់រដ្ឋបាលកណ្តាលដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការអនុវត្ត នូវអំណាច ឬមុខងារក្នុងនាមខ្លួនជារដ្ឋបាលកណ្តាល ដោយផ្តល់នូវធនធាន ឬកម្រៃសេវា និងការបង្កើនសមត្ថភាព ហើយរដ្ឋបាលមូលដ្ឋានទទួលខុសត្រូវចំពោះរដ្ឋបាលកណ្តាល ចំណែករដ្ឋបាលកណ្តាលនៅតែទទួលខុសត្រូវជាចុងក្រោយចំពោះមុខច្បាប់ ។ | |
| **៨. តើអ្វីទៅជាអត្ថន័យ នៃ *ភាពជាតំណាងតាមបែបលទ្ធិប្រជាធិតេយ្យ* ដែលជាធាតុមួយនៃគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ ?** | |
| ក) កំណែទម្រង់នឹងពង្រឹងតួនាទីរបស់ក្រុមប្រឹក្សាតាមថ្នាក់រដ្ឋបាល ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែលបង្កើតឡើងតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ដោយពង្រីកអំណាច ភារកិច្ច ការទទួលខុសត្រូវ និងធនធាន ។ | ✓ |
| ខ) កំណែទម្រង់នឹងរៀបចំប្រព័ន្ធ និងទម្រង់ការនានា សម្រាប់ប្រជាពលរដ្ឋ ពិសេសស្ត្រី និងក្រុមជនងាយរងគ្រោះ ក្រុមជនជាតិដើមភាគតិចអាចចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត នៅតាមបណ្តាថ្នាក់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ។ | |
| គ) កំណែទម្រង់នឹងពង្រឹងគណនេយ្យភាពនៅគ្រប់លំដាប់ថ្នាក់រដ្ឋបាល និងសម្រួលការចូលរួមពិនិត្យមើលរបស់ប្រជាពលរដ្ឋក្នុងដំណើរការការអនុវត្តតួនាទី និងភារកិច្ច និងអនុវត្តសេចក្តីសម្រេចចិត្ត ហើយទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ដោយរាយការណ៍និងបញ្ជាក់ពីមូលហេតុដែលខ្លួនបានសម្រេច និងបានអនុវត្ត ។ | |

| | |
|---|---|
| ឃ) កំណែទម្រង់នឹងនាំសេវាសាធារណៈឱ្យទៅកៀកនឹងអ្នកប្រើប្រាស់ ដោយអនុញ្ញាតឱ្យប្រជា ពលរដ្ឋបានចូលរួមក្នុងការរៀបចំផែនការនិងការត្រួតពិនិត្យសេវាសាធារណៈទាំងនោះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងអាទិភាពរបស់មូលដ្ឋាន ។ | |

| ៩. តើអ្វីទៅជាអត្ថន័យនៃ*ការចូលរួមរបស់ប្រជាពលរដ្ឋ* ដែលជាធាតុមួយនៃគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ? | |
|---|---|
| ក) កំណែទម្រង់នឹងពង្រឹងតួនាទីរបស់ក្រុមប្រឹក្សាតាមថ្នាក់រដ្ឋបាល ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែលបង្កើតឡើងតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ដោយពង្រីក អំណាច ភារកិច្ច ទទួលខុសត្រូវ និងធនធាន។ | |
| ខ) កំណែទម្រង់នឹងរៀបចំប្រព័ន្ធ និងទម្រង់ការនានា សម្រាប់ប្រជាពលរដ្ឋ ពិសេសស្ត្រី និងក្រុមជនងាយរងគ្រោះ ក្រុមជនជាតិដើមភាគតិច អាចចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅ តាមបណ្តាថ្នាក់រដ្ឋបាល ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ | ✓ |
| គ) កំណែទម្រង់នឹងពង្រឹងគណនេយ្យភាពនៅគ្រប់លំដាប់ថ្នាក់រដ្ឋបាលនិងសម្រួលការចូលរួមពិនិត្យមើលរបស់ប្រជាពលរដ្ឋ ក្នុងដំណើរការការអនុវត្ត តួនាទី និងភារកិច្ច និងអនុវត្តសេចក្តី សម្រេចចិត្ត ហើយទទួល ខុសត្រូវចំពោះទង្វើរបស់ខ្លួន ដោយរាយការណ៍និងបញ្ជាក់ពីមូលហេតុដែលខ្លួនបានសម្រេច និងបានអនុវត្ត។ | |
| ឃ) កំណែទម្រង់នឹងនាំសេវាសាធារណៈឱ្យទៅកៀកនឹងអ្នកប្រើប្រាស់ ដោយអនុញ្ញាតឱ្យប្រជាពលរដ្ឋបានចូលរួមក្នុងការរៀបចំផែនការ និងការត្រួតពិនិត្យសេវាសាធារណៈទាំងនោះ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនិងអាទិភាពរបស់មូលដ្ឋាន។ | |
| **១០. តើអ្វីទៅជាអត្ថន័យ នៃ *គណនេយ្យភាពនៃវិស័យសាធារណៈ* ដែលជាធាតុមួយនៃគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ?** | |
| ក) កំណែទម្រង់នឹងពង្រឹងតួនាទីរបស់ក្រុមប្រឹក្សាតាមថ្នាក់រដ្ឋបាល ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ដែលបង្កើតឡើងតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ដោយពង្រីកអំណាចភារកិច្ចទទួលខុសត្រូវ និងធនធាន។ | |
| ខ) កំណែទម្រង់នឹងរៀបចំប្រព័ន្ធ និងទម្រង់ការនានា សម្រាប់ប្រជាពលរដ្ឋ ពិសេសស្ត្រី និងក្រុមជនងាយរងគ្រោះ ក្រុមជនជាតិដើមភាគតិច អាចចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅ តាមបណ្តាថ្នាក់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ | |
| គ) កំណែទម្រង់នឹងពង្រឹងគណនេយ្យភាពនៅគ្រប់លំដាប់ថ្នាក់រដ្ឋបាលនិងសម្រួលការចូលរួមពិនិត្យមើលរបស់ប្រជាពលរដ្ឋក្នុងដំណើរការការអនុវត្ត តួនាទី និងភារកិច្ច និងអនុវត្តសេចក្តីសម្រេចចិត្ត ហើយទទួលខុសត្រូវចំពោះ ទង្វើរបស់ខ្លួន ដោយរាយការណ៍និងបញ្ជាក់ពីមូលហេតុដែលខ្លួនបានសម្រេច និងបានអនុវត្ត។ | ✓ |
| ឃ) កំណែទម្រង់នឹងនាំសេវាសាធារណៈឱ្យទៅកៀកនឹងអ្នកប្រើប្រាស់ដោយអនុញ្ញាតឱ្យប្រជាពលរដ្ឋបានចូលរួមក្នុងការរៀបចំផែនការ និងការត្រួតពិនិត្យសេវាសាធារណៈទាំងនោះ ដើម្បីឆ្លើយតបទៅនឹង តម្រូវការ និងអាទិភាព របស់មូលដ្ឋាន។ | |

## SESSION 5: ទស្សនទានសំខាន់ៗនៃសេចក្តីព្រាងច្បាប់រៀបចំអង្គការ

| | | |
|---|---|---|
| **១១- តើឯកសារផ្លូវច្បាប់អ្វីដែលសេចក្តីព្រាងច្បាប់រៀបចំអង្គការប្រើជាមូលដ្ឋាន ?** | | |
| ក) | ព្រះរាជក្រឹត្យស្តីពីការបង្កើត គណៈកម្មាធិការជាតិ ដឹកនាំការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។ | |
| ខ) | ក្របខ័ណ្ឌយុទ្ធសាស្ត្រ ស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។ | ✓ |
| គ) | ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ ។ | |
| ឃ) | រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា | |
| **១២- តើស្ថាប័នណាមួយទទួលខុសត្រូវក្នុងការរៀបចំសេចក្តីព្រាងច្បាប់រៀបចំអង្គការ ?** | | |
| ក) | ក្រសួងមហាផ្ទៃ | |
| ខ) | គណៈកម្មាធិការជាតិ ដឹកនាំការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | ✓ |
| គ) | ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | |
| ឃ) | ទីស្តីការគណៈរដ្ឋមន្ត្រី | |
| **១៣- តើសមាសភាពនៃសេចក្តីព្រាងច្បាប់រៀបចំអង្គការបឋម មានអ្វីខ្លះ ?** | | |
| ក) | (1) ក្រុមប្រឹក្សា ( 2) បុគ្គលិក (3) ការបោះឆ្នោត | |
| ខ) | (1) ក្រុមប្រឹក្សា (2) គណៈកម្មាធិការក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សា អភិបាល (3) បុគ្គលិក | |
| គ) | (1) ក្រុមប្រឹក្សា (2) គណៈកម្មាធិការក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សា អភិបាល (3) បុគ្គលិក (4) ក្រុមប្រឹក្សាជាតិ ការអនុវត្តមុខងារ និងធនធាន | |
| ឃ) | (1) ក្រុមប្រឹក្សា (2) គណៈកម្មាធិការក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សា អភិបាល (3) បុគ្គលិក (4) ក្រុមប្រឹក្សាជាតិ ការអនុវត្ត មុខងារ និងធនធាន (5) ការបោះឆ្នោត | ✓ |
| **១៤-តំបន់ប្រជុំជននឹងត្រូវគ្រប់គ្រងខុសពីតំបន់ជនបទដោយអនុលោមតាមសេចក្តីព្រាងច្បាប់រៀបចំអង្គការលើកដំបូង។ ខាងក្រោមនេះ តើផ្នែកណាមួយដែលចាត់ទុកជាតំបន់ប្រជុំជន ?** | | |
| ក) | ក្រុងភ្នំពេញ | |
| ខ) | ក្រុងភ្នំពេញ ក្រុងព្រះសីហនុ ក្រុងកែប និងក្រុងប៉ៃលិន | |
| គ) | ក្រុងភ្នំពេញ ខេត្តសៀមរាប និង ខេត្តបាត់ដំបង | |
| ឃ) | ក្រុងភ្នំពេញ និងតំបន់ប្រជុំជនផ្សេងៗទៀតដូចជាក្រុងព្រះសីហនុ ស្រុកបាត់ដំបង ស្រុកសៀមរាប និងឃុំ ប៉ោយប៉ែត ។ | ✓ |

| ១៥-តើប្រយោគណាមួយខាងក្រោម ដែលទាក់ទងនឹងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដែលផ្ទុយពីសេចក្តីព្រាងច្បាប់ រៀបចំអង្គការ លើកតំបូង ? | | |
|---|---|---|
| ក) | គណៈកម្មាធិការគ្រប់គ្រងក្រុមប្រឹក្សាត្រូវតែជ្រើសរើសឡើង ដោយសមាជិកក្រុមប្រឹក្សា ចំពោះក្រុមប្រឹក្សាណា ដែលមានសមាជិកច្រើន ។ | |
| ខ) | ក្រុមប្រឹក្សានីមួយៗ ត្រូវតែមាន **ក្រុមប្រឹក្សាផ្តល់យោបល់ផ្នែកបច្ចេកទេស** | |
| គ) | ក្រុមប្រឹក្សានីមួយៗ ត្រូវតែបង្កើត **គណៈកម្មាធិការលទ្ធកម្ម** | |
| ឃ) | ក្រុមប្រឹក្សានីមួយៗ ត្រូវតែបង្កើត **គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី** | ✓ |

## SESSION 9: ករណីសិក្សា : ការិយាល័យច្រកចេញ ចូលតែមួយ

| **១៦. តើស្រុកណាខ្លះ ដែលត្រូវបានគេរៀបចំជាស្រុកគម្រូតាមខ្លឹមសារនៃសេចក្តីសម្រេចលេខ ៤៧?** | |
|---|---|
| ក) ស្រុក សៀមរាប | |
| ខ) ស្រុកបាត់ដំបង | |
| គ) ស្រុកសៀមរាប និងស្រុកបាត់ដំបង | ✓ |
| ឃ) ស្រុកសៀមរាប ស្រុកបាត់ដំបង និងស្រុកកំពង់ចាម | |
| **១៧. តើការិយាល័យច្រកចេញ ចូលតែមួយត្រូវបានបង្កើតឡើងក្រោមរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ណាមួយ?** | |
| ក) រដ្ឋបាលថ្នាក់ជាតិ | |
| ខ) រដ្ឋបាលថ្នាក់ខេត្ត ក្រុង | |
| គ) រដ្ឋបាលស្រុក ខណ្ឌ | ✓ |
| ឃ) រដ្ឋបាលឃុំ សង្កាត់ | |
| **១៨. តើការិយាល័យច្រកចេញចូលតែមួយបង្កើតឡើងដើម្បីអ្វី?** | |
| ក) ផ្តល់សេវាកម្មសាធារណៈដល់ប្រជាពលរដ្ឋ សហគ្រាស និងអង្គការ ស្ថាប័នដែលធ្វើសកម្មភាពក្នុងដែនដីស្រុករបស់ខ្លួន | ✓ |
| ខ) រៀបចំផែនការថវិកាស្រុក និងតាមដានការប្រើប្រាស់ថវិកាស្រុក | |
| គ) ប្រឆាំងការប្រព្រឹត្តិអំពើពុករលួយដែលប្រព្រឹត្តិដោយមន្ត្រីរាជការ និងបង្កើតទំនាក់ទំនងល្អ និងភាពជឿជាក់រវាងរដ្ឋបាលស្រុក និងប្រជាពលរដ្ឋ សហគ្រិនដែលមានទីតាំងនៅក្នុងស្រុករបស់ខ្លួន | |

| | |
|---|---|
| ឃ) ជួយដោះស្រាយជំលោះរបស់ប្រជាពលរដ្ឋ ដោយអនុវត្តន៍តាមបទបញ្ញា និងនិតិវិធីដែលមានចែងក្នុងច្បាប់ | |

| | |
|---|---|
| **១៩. តើប្រយោគណាមួយ ក្នុងចំណោមប្រយោគខាងក្រោមដែលពន្យល់បានល្អជាងគេ ពីសេវាកម្មដែលផ្តល់ដោយការិយាល័យច្រកចេញ ចូលតែមួយ?** | |
| ក) ផ្តល់សេវាកម្មលឿន ហើយមានតម្លៃថោក | ✓ |
| ខ) ការផ្តល់សេវាកម្មលឿនជាងមុន ប៉ុន្តែថ្លៃសេវានៅរក្សា តម្លៃដូចមុន | |
| គ) ថ្លៃសេវាមានតម្លៃថោកជាងមុន ប៉ុន្តែរយៈពេលផ្តល់សេវានៅរក្សាដូចមុន | |
| ឃ) ថ្លៃសេវា និងរយៈពេលផ្តល់សេវា នៅរក្សាដូចមុនដដែល | |
| **២០.ក្នុងចំណោមប្រយោគខាងក្រោម តើប្រយោគណាមួយដែលនិយាយពីភាពខ្លាំងរបស់ការិយាល័យច្រកចេញ ចូលតែមួយ ប៉ុន្តែមិនត្រឹមត្រូវ ?** | |
| ក) ការិយាល័យច្រកចេញ ចូលតែមួយមានទីតាំងការិយាល័យនៅចំចំនណុចកណ្តាល ដែលធ្វើឱ្យពួកគេងាយស្រួលជួបនឹងប្រជាពលរដ្ឋ។ | |
| ខ) ការិយាល័យច្រកចេញចូលតែមួយ មានម៉ោងធ្វើការងារបម្រើអតិថិជនបានល្អ គឺចាប់ពីម៉ោង៧.៣០-៩.៣០នាទីព្រឹក | ✓ |
| គ) តម្លៃនៃប្រភេទសេវាខុសៗគ្នា ត្រូវបានគេសរសេរលើផ្ទាំងក្តារ ដ៏ធំដែលអ្នកគ្រប់គ្នាអាចមើលឃើញ។ | |
| ឃ) ក្រុមការងារនៃការិយាល័យច្រកចេញ ចូលតែមួយមានចិរតសុភាពរាបសារ និងមានទំនាក់ទំនងល្អ ចេះជួយ ប្រជាពលរដ្ឋ | |

**ឧបសម្ព័ន្ធ ៣**

## សំណួរនានាស្តីពីការអង្កេតលើផលប៉ះពាល់

១. តើវគ្គបណ្តុះបណ្តុះបណ្តាល/សិក្ខាសាលាទាំងមូលបានផ្តល់អត្ថប្រយោជន៍ដល់ការងាររបស់អ្នកដែរឺទេ? (បាទ/ចាំ, ទេ)

២. ប្រសិនបើ "បាទ/ចាំ" ចូរពន្យល់ថាហេតុអ្វីបានជាវាផ្តល់អត្ថប្រយោជន៍ ។ប្រសិនបើ "ទេ" រឺក៏ "មិនដឹង" ចូរពន្យល់ពីមូលហេតុ ?

| |
|---|
| |

៣. តើមានចំណេះដឹងជាក់លាក់ណាមួយទេស្តីពីគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងច្បាប់រៀបចំអង្គការ ដែលអ្នកបានប្រើប្រាស់នៅកន្លែងការងាររបស់អ្នកដែរឺទេ បន្ទាប់ពីទទួលបានការបណ្តុះបណ្តាល ? (បាទ/ចាំ ,ទេ)

៤. ប្រសិនបើឆ្លើយ "បាទ/ចាំ"ចូរឱ្យឧទាហរណ៍ជាក់លាក់មួយ ។ប្រសិនបើឆ្លើយ "ទេ" រឺ "មិនដឹង" ចូរពន្យល់ពីមូលហេតុ ?

| |
|---|
| |

៥. តើអ្នកមានបានប្រើប្រាស់សម្ភារៈបណ្តុះបណ្តាលដែររឺទេ បន្ទាប់ពីអ្នកបានចូលរួមក្នុងវគ្គបណ្តុះបណ្តាល រឺសិក្ខាសាលា? (បាន, មិនបាន)

៦. ប្រសិនបើឆ្លើយថា "បាន" តើសម្ភារៈបណ្តុះបណ្តាលអ្វីខ្លះដែលអ្នកបានប្រើប្រាស់ ហើយប្រើក្នុងគោលបំណងអ្វី ។ ប្រសិនបើឆ្លើយថា "ទេ" រឺ "មិនដឹង" ចូរពន្យល់ពីមូលហេតុ ?

| |
|---|
| |

៧. តើអ្នកមានបានប្រើប្រាស់អ្វីដែលអ្នកបានរៀនពីក្នុងវគ្គបណ្តុះបណ្តាល/សិក្ខាសាលា នៅក្នុងការងាររបស់អ្នកទេ ? (បាន, មិនបាន)

៨. ប្រសិនបើឆ្លើយថា "បាន" ចូរលើកឧទាហរណ៍ យ៉ាងហោចណាស់មួយ ។ ប្រសិនបើឆ្លើយថាមិន "មិនបាន" រឺ "មិនដឹង" ចូរពន្យល់ពីមូលហេតុ ?

៩. ដោយសារតែវគ្គបណ្តុះបណ្តាល រឺសិក្ខាសាលាតើអ្នកមានបានផ្លាស់ប្តូរនូវការយល់ឃើញ អត្តចរិក រឺឥរិយាបទអ្វីខ្លះដែររឺទេ ?

១០. ប្រសិនបើឆ្លើយថា “បាន” ចូរលើកឧទាហរណ៍ជាក់លាក់យ៉ាងហោចណាស់មួយ

១១. តើការគាំទ្របន្ថែមអ្វីខ្លះទៀតដែលជួយអ្នកឱ្យធ្វើការងារបានប្រសើរជាមុន ?

១២. តើអ្នកមានអនុសាសន៍ រឺមតិយោបល់អ្វីខ្លះទេដើម្បីកែលម្អលវគ្គបណ្តុះបណ្តាល រឺសិក្ខាសាលា?

ឧសម្ព័ន្ធ ៤

# គំរូទម្រង់បញ្ចូលទិន្នន័យ

## វគ្គបណ្តុះបណ្តាលមន្ត្រី អ.វ.ម



Appendix 5

# បញ្ជីផ្ទៀងផ្ទាត់របាយការណ៍វាយតម្លៃ

**1. ចំណងជើងទំព័រ :**

- ចំណងជើងត្រូវកំណត់ពីអ្វីដែលត្រូវវាយតម្លៃដោយរាប់បញ្ចូលទាំងក្រុមគោលដៅផងបើសិនអាចធ្វើបាន
- ចំណងជើងត្រូវតែច្បាស់លាស់ និងខ្លី ដើម្បីសំរួលដល់ការរៀបចំតារាងអក្សររៀបរៀងឈ្មោះសៀវភៅ
- បង្ហាញឈ្មោះអ្នកនិពន្ធ និងទំនាក់ទំនង
- កាលបរិច្ឆេទការរៀបចំ
- អត្ថបទ និងឯកសារនៅចំណងជើងទំព័រត្រូវតែច្បាស់លាស់ និងរៀបចំឱ្យបានត្រឹមត្រូវ

2. **សេចក្តីសង្ខេប**

- ពណ៌នាពីគម្រោង/កម្មវិធី :
- សំណួរវាយតម្លៃ និងគោលបំណងនៃការវាយតម្លៃ
- សង្ខេបពី របកគំហើញសំខាន់ៗ
- ផ្តល់ជាអនុសាសន៍ ប្រសិនបើអាចធ្វើបាន
- សង្ខេប និងពណ៌នាពីរចនាសម្ព័ន្ធនៃរបាយការណ៍

3. **តារាងមាតិកា និងផ្នែកផ្សេងៗដែលមាននៅខាងដើមនៃរបាយការណ៍**

- តារាងមាតិកាត្រូវមានយ៉ាងហោចណាស់ចំណងជើងធំ និងចំណងជើងរងនៃរបាយការណ៍
- ចំណងជើង និងទំព័រត្រូវតែច្បាស់លាស់
- បញ្ជីតារាង ក្រាភិច ដ្យាក្រាម និងឧបសម្ព័ន្ធត្រូវមានភ្ជាប់ផងដែរ បើអាចធ្វើបាន
- អត្ថបទទទួលស្គាល់ ជាមួយនិងឯកសារយោងរបស់អ្នកឧបត្ថម្ភ អ្នកប្រមូលព័ត៌មាន.... ។ល។
- តារាងពាក្យកាត់ត្រូវមានភ្ជាប់បើអាចធ្វើបាន

**4. ការពណ៌នាពីកម្មវិធី :**

- ការពណ៌នាពីកម្មវិធីដែលត្រូវធ្វើការវាយតម្លៃ ( រាប់បញ្ចូលទាំង ប្រវត្តិ បរិបទ បើនអាចធ្វើបាន )
- កំណត់ក្រុមគោលដៅដែលជាសិក្ខាកាម
- ពណ៌នាពីសកម្មភាពរបស់គម្រោង

**5. ការបង្កើតទម្រង់វាយតម្លៃ និងរូបមន្ត :**

- ❑ គោលបំណងនៃការវាយតម្លៃ និងសំណួរវាយតម្លៃ
- ❑ វិធីសាស្ត្រវាយតម្លៃ ដែលយកមកប្រើប្រាស់
- ❑ រូបមន្តនៃការប្រមូលព័ត៌មាន
- ❑ រៀបចំបង្កើតទម្រង់វាយតម្លៃ ដោយរាប់បញ្ចូលទាំង ពេលវេលានៃការប្រមូលព័ត៌មាន និងការប្រើរូបមន្តប្រមូល ទិន្នន័យជាក់លាក់
- ❑ ប្រភពព័ត៌មាន និងទិន្នន័យ
- ❑ ព្រំដែននៃការវាយតម្លៃ

6. **របកគំហើញ និងលទ្ធផល :**

- ❑ បរិយាយពីរបកគំហើញឱ្យបានច្បាស់ និងសមហេតុផល
- ❑ ក្រាភិច តារាង ដ្យាក្រាម ត្រូវដាក់ចំណងជើងឱ្យបានច្បាស់លាស់ និងងាយយល់
- ❑ ពិភាក្សាលើរបកគំហើញ គឺរាប់បញ្ចូលទាំងរបកគំហើញវិជ្ជមាន និងអវិជ្ជមាន។ គ្រប់សំណួរវាយតម្លៃត្រូវតែមានការឆ្លើយតប និងពន្យល់ឱ្យបានច្បាស់លាស់ពីមូលហេតុនៃសំណួរ ដែលមិនមានការឆ្លើយតប
- ❑ របកគំហើញគឺត្រូវបានកែតម្រូវយ៉ាងហ្មត់ចត់

**7. សន្និដ្ឋាន និងអនុសាសន៍ :**

- ❑ ពិភាក្សា និងធ្វើការបកស្រាយលើរបកគំហើញ
- ❑ សង្ខេប និងសន្និដ្ឋានយ៉ាងត្រឹមត្រូវ ដោយមានការឆ្លើយតបនឹងរបកគំហើញ
- ❑ ការវិនិច្ឆ័យទៅលើចំណុចល្អ និងចំណុចខ្វះខាតរបស់កម្មវិធី
- ❑ បើអាច ត្រូវផ្តល់ជាអនុសាសន៍ ដោយយោងតាមលទ្ធផលនៃរបកគំហើញ

**8. ឯកសារយោង និង ឧបសម្ព័ន្ធ :**

- ❑ ទម្រង់សមស្របមួយត្រូវបានប្រើប្រាស់ជាប្រចាំសម្រាប់ឯកសារយោងទាំងអស់
- ❑ ឯកសារយោងមិនឱ្យមានកំហុស
- ❑ ត្រូវមានឯកសារយោងរាល់ការដកស្រង់អត្ថបទផ្សេងៗ
- ❑ ត្រូវមានបញ្ចូលឧបសម្ព័ន្ធភ្ជាប់
- ❑ ព័ត៌មាន និងទិន្នន័យក្នុងឧបសម្ព័ន្ធត្រូវតែមានពន្យល់ច្បាស់លាស់

*ប្រភព: Adopted from Torres, Rosalie T., et al. (2005). Evaluation Strategies for Communicating And Reporting. Sage Publications.*